ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២០-៦-២០១៣ -ព្រះរាជក្រម នស/រកម/០៦១៣/០១២ ស្តីពី វិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ៥៨០០


### ២~ព្រះរាជក្រឹត្យ


០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងសប្បុរសជន ចំនួន ១១ អង្គ/ រូប ៥៨០២

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ជនជាតិវៀតណាម និងក្រុមការងារសាងសង់ ចំនួន ០៦ រូប ៥៨០៣

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និងមន្ត្រីរាជការ ចំនួន ៤២ រូប ៥៨០៤

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ លោកជំទាវ ឆោម សោភ័ណ្ឌី ៥៨០៦

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៩ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១៩៨,៥០ ហិកតា ចេញពីដីជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ៥៨០៧

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦០០ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១.៤៣០,០១ ហិកតា ចេញពីដីជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ៥៨០៨

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦០១ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៩១៩,៥៦ ហិកតា ចេញពីដីជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ៥៨០៩

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦០២ ស្តីពី ការកាត់ផ្ទៃដី ទំហំ ២២១,៥០ ហិកតា ចេញពីដីជម្រកសត្វព្រៃភ្នំព្រេច ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៥ ៥៨១០

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦០៣ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១.០៤៨,៣៣ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ៥៨១១

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦០៤ ស្តីពី ការកាត់ផ្ទៃដី ទំហំ ៤៧៦,៨៨ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ៥៨១២

០៩-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៦០៥ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១៧៥,៧៨ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ៥៨១៣

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៩០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៧០,៥៩ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩៧ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៨១៤

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៩១ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៤១២ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះកាត់ចេញពីដីសម្បទានព្រៃឫស្សី របស់ក្រុមហ៊ុនភាពីម៉ិច និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វ័ត្ថសម្បត្តិ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.០០០ គ្រួសារ ៥៨១៧

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៩២ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៩.០៦៧ ហិកតា នៅស្រុករលាប្អៀរ ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្នុងនោះកាត់ចេញពីដីអតីតសហគ្រាសសេរី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុនភាពីម៉ិច និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤.៥៤៩ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសហគមន៍ និងជាដីសាធារណៈរបស់រដ្ឋ ៥៨២០

៣១-៥-២០១៣ - អនុក្រឹត្យលេខ ២៩៣ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ១.០០៧,៣៩ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពី (១) ដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុនGrands Timber LTD ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់ រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៨២៥

៣១-៥-២០១៣ - អនុក្រឹត្យលេខ ២៩៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៤៩៤,៦៧ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពី (១) ដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនGrands Timber LTD ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩១ គ្រួសារ និងរក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥៨២៨

៣១-៥-២០១៣ - អនុក្រឹត្យលេខ ២៩៥ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ២.៤២២ ហិកតា នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចេញពីដីព្រៃសម្បទានព្រៃឫស្សី របស់ក្រុមហ៊ុនភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧២៩ គ្រួសារ ៥៨៣១

៣១-៥-២០១៣ - អនុក្រឹត្យលេខ ២៩៦ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៤៤១,៦៤ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពី (១) ដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនGrands Timber LTD ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៨៣៤

៣១-៥-២០១៣ - អនុក្រឹត្យលេខ ២៩៧ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ១.៤៧៣,៧៤ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៨៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៥៨៣៧

០២-៤-២០១៣ - អនុក្រឹត្យលេខ ៣៨៩ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៥៨៤០

០៣-៤-២០១៣ - អនុក្រឹត្យលេខ ៣៩០ អនក្រ.តត ស្ដីពី ការផ្លាស់ប្ដូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ៥៨៤៣

០៣-៤-២០១៣ - អនុក្រឹត្យលេខ ៣៩១ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៥៨៤៦

*-អនុក្រឹត្យលេខ ៣៩២ អនក្រ.តត មិនទាន់បានទទួល*

០៣-៤-២០១៣ - អនុក្រឹត្យលេខ ៣៩៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៥៣

០៣-៤-២០១៣ - អនុក្រឹត្យលេខ ៣៩៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៥៤

០៣-៤-២០១៣ - អនុក្រឹត្យលេខ ៣៩៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៨៥៦

០៣-៤-២០១៣ -អនុក្រឹត្យលេខ ៣៩៦ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥៨៥៩
០៣-៤-២០១៣ -អនុក្រឹត្យលេខ ៣៩៧ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៥៨៦១
០៣-៤-២០១៣ -អនុក្រឹត្យលេខ ៣៩៨ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៥៨៦៣
០៣-៤-២០១៣ -អនុក្រឹត្យលេខ ៣៩៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៨៦៤
០៣-៤-២០១៣ -អនុក្រឹត្យលេខ ៤០០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៨៦៦
០៣-៤-២០១៣ -អនុក្រឹត្យលេខ ៤០១ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៥៨៦៧
០៤-៤-២០១៣ -អនុក្រឹត្យលេខ ៤០២ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាន់ខ្ពស់ ៥៨៦៨
០៤-៤-២០១៣ -អនុក្រឹត្យលេខ ៤០៣ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨៦៩
០៤-៤-២០១៣ -អនុក្រឹត្យលេខ ៤០៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៨៧០
០៤-៤-២០១៣ -អនុក្រឹត្យលេខ ៤០៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៧២
០៤-៤-២០១៣ -អនុក្រឹត្យលេខ ៤០៦ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨៧៤

## ២-សារាចរ

២៩-៥-២០១៣ -សារាចរលេខ ០៣ សរ ស្ដីពី ការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ៥៨៧៥

## III-ការិយាល័យក្រសួង

## ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៩-៦-២០១៣ -ប្រកាសលេខ ៥៩៨ សហវ.ប្រក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ៥៩២១
១៩-៦-២០១៣ -ប្រកាសលេខ ៥៩៩ សហវ.ប្រក ស្ដីពី ការតែងតាំងសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ៥៩២៥

# ព្រះរាជក្រម

នស/រកម/០៦១៣/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១២៧/០០២/២០១៣ កបធ.ច ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅ
# នៃគណៈរដ្ឋមន្ត្រី

**មាត្រាមួយ.-**

មាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ២៨.-ថ្មី**

ប្រធានស្ថាប័នមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន វរសេនីយ៍ឯកនិងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ ប្រធានស្ថាប័នមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានដោយប្រកាសចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល ។

រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម/០៦១៣/០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ**

**សូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

លេខ ១៧៧ ស.ណ

**សំណៅចម្លងដែលមានការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊ឹម សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងសប្បុរសជន ចំនួន ១១ អង្គ/រូប មានគុណបំណាច់ និងស្នាដៃល្អក្នុងការបំពេញការងារជូនជាតិមាតុភូមិ និងចូលរួមចំណែកក្នុងការស្តាបនាជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ សម្រេចបានលទ្ធផលល្អប្រសើរ

**នូវ**

ក- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ មហាសេរីវឌ្ឍន៍
- ១- ព្រះតេជគុណ **អ៊ី សម្បត្តិ**
- ២- ព្រះតេជគុណ **ណុប ចាន់ឌី**

ខ- គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ**
- ១- ឯកឧត្តម **សំ ចណ្ណសិទ្ធ**
- ២- ឯកឧត្តម **គឿន ភិរម្យ**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ មហាសេនា
- ១- ឯកឧត្តម **នឹង ខាន់ថូ**
- ២- ឯកឧត្តម **ហ៊ឹម ប៊ុណ្ណារ៉ា**
- ៣- លោកជំទាវ **សំ ច័ន្ទធា**
- ៤- លោក **ខឹម ច័ន្ទគិរី**
- ៥- លោក **ខួន សឿន**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា
- ១- លោក **នឹង ខាន់ដេត**
- ២- កញ្ញា **សំ ចណ្ណថុល**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៣០៦.៤០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣*

លេខៈ ៥៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាសិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

**ចំពោះ**

សប្បុរសជនជនជាតិវៀតណាមនិងក្រុមការងារសាងសង់ ចំនួន០៦រូប ដែលមានគុណបំណាច់និងស្នាដៃល្អក្នុងការជួយឧបត្ថម្ភថវិកាកសាងអគារសិក្សាថ្មីមួយខ្នង កំពស់៣ជាន់ មាន៣០បន្ទប់ នៃវិទ្យាល័យស្ទឹងត្រង់ ស្ថិតនៅក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

**នូវ**

**ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោក DUONG CONG MINH
២-លោក LE VAN KIEM
៣-អ្នកស្រី TRAN CAM NHUNG

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

ឧកញ៉ា សុខ ហុង

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

១-លោក ផុង ឈាន់
២-លោក វ៉ាហេង ជាវុធ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារនៈ ១៣០៦.២០១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ ៥៩ ស.ណ
**សំណៅចម្លងមានបញ្ជូនជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៧

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និងមន្ត្រីរាជការចំនួន ៤២រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធាន
ផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាលើគ្រប់វិស័យ ស្ថិតនៅក្នុងខេត្តព្រះសីហនុ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-លោកវរសេនីយ៍ឯក **សុខ ពិសិដ្ឋ**
២-លោកវរសេនីយ៍ទោ **ឯម សុគន្ធ**
៣-លោកវរសេនីយ៍ទោ **ចំរើន ណោតធារីសំរេច**
៤-លោកវរសេនីយ៍ត្រី **ជិន សាកែម**
៥-លោកវរសេនីយ៍ត្រី **ស្រេង សុខា**
៦-លោកវរសេនីយ៍ត្រី **ខឡ្យ សារី**
៧-លោកវរសេនីយ៍ត្រី **ប៊ី ណាស៊ុ**
៨-លោកវរសេនីយ៍ត្រី **តុប ទុន្ធា**
៩-លោកវរសេនីយ៍ត្រី **ហ៊ន់ លីគា**
១០-លោកវរសេនីយ៍ត្រី **តាក សារិទ្ធ**
១១-លោកអនុសេនីយ៍ឯក **ស៊ា ស៊ីណាល**
១២-លោកអនុសេនីយ៍ឯក **ឈឹម ដារ៉ាទុង**
១៣-លោកអនុសេនីយ៍ឯក **អ៊ី ចំរើន**
១៤-លោកអនុសេនីយ៍ឯក **កៅ សារ៉ាណា**
១៥-លោកអនុសេនីយ៍ឯក **ខៃ តិប**
១៦-លោកអនុសេនីយ៍ឯក **សេង សំអុន**
១៧-លោកអនុសេនីយ៍ឯក **ឆាយ ជៀស**
១៨-លោកអនុសេនីយ៍ឯក **ដុំ សារិន**
១៩-លោកអនុសេនីយ៍ឯក **ណុប ភារិន្ត**
២០-លោកអនុសេនីយ៍ទោ **សុខ សារឿន**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

២១-លោកអនុសេនីយ៍ទោ ស្រេង គា
២២-លោកអនុសេនីយ៍ទោ ទូច សម្បត្តិ
២៣-លោកអនុសេនីយ៍ទោ ឆាន សុខខេង
២៤-លោកអនុសេនីយ៍ទោ ឈូ សារ៉ាធុច
២៥-លោកអនុសេនីយ៍ទោ គង លីដេត
២៦-លោកអនុសេនីយ៍ទោ ឌិន សុខកុមារ
២៧-លោកអនុសេនីយ៍ទោ សៀង សុភារ័ត្ន
២៨-លោកអនុសេនីយ៍ត្រី អូត ស៊ីធុត្ថា
២៩-លោកអនុសេនីយ៍ត្រី មួន ចន្ថា
៣០-លោកអនុសេនីយ៍ត្រី មួង សេងហួង
៣១-លោក ឃុត សាលីន
៣២-លោក រស់ អៀម

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ សេនា :

១-លោកស្រីវរសេនីយ៍ទោ ហួន គីមហេង
២-លោកវរសេនីយ៍ទោ គង់ កុលធីរៈ
៣-លោកវរសេនីយ៍ទោ ម៉ែន ខេមរិទ្ធ
៤-លោកវរសេនីយ៍ត្រី ស្រ៊ុន សុជាតិ
៥-លោកវរសេនីយ៍ត្រី ឈុន សំអូន
៦-លោកអនុសេនីយ៍ទោ តូច ចាន់ប៊ុនលី
៧-លោកអនុសេនីយ៍ត្រី ម៉ែត កញ្ញា
៨-លោកអនុសេនីយ៍ត្រី សម្បត្តិ កុសល

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរកត.១៣០៦.៦០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ [illegible] ស.ណ
សំណៅដែលមានតម្លៃស្មើការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

លោកជំទាវ ញឹម សោភ័ណ្ឌរី

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តាមលិ. ១៣០៦.៦០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៦៣៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខា[illegible]រាជរដ្ឋាភិបាល**

**សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ១៩៨.៥០ ហិកតា ចេញពីដែនជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៨.១៣០៦.៦១០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៣

លេខ ៥៩៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦០០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ១.៤៣០,០១ ហិកតា ចេញពីដីជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ.១៣០៦.៦១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៥៩៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ៩១៩.៥៦ ហិកតា ចេញពីដែនជម្រកសត្វព្រៃបឹងពែរ ដែលកំណត់ដោយព្រះរាជ-ក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៣ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]. ១៣០៦. ៦០២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៣*

លេខ: ៥៩៧ ស.ណ
**សំណៅដែលបានថតចម្លងជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ២២១,៥០ ហិកតា ចេញពីដីជម្រកសត្វព្រៃភ្នំព្រេច ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៥ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧-១៣០៦.៦១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ ៥៥៤ ស.ណ
**សំណៅចម្លង[illegible]ការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ១.០៤៨,៣៣ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣០.១៣០៦.៦២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ ៦០០ ស.ណ
**សំណៅដែលមានអត្ថន័យដូចការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៦០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ៩៧៦,៨៨ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ក្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣*

លេខៈ [illegible] ស.ណ
**សំណៅដែលមានត្រឹមត្រូវជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/២០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** កាត់ផ្ទៃដីទំហំ ១៧៥,៧៨ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ៨ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៥៧.១៣០៦.២១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ ៧០១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៩៧០,៥៩ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ២៩៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៥១អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ៩៧០,៥៩ហិកតា ចេញពីដីតម្រូវព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៩០០,៩៧ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៦៩,៦២ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិត្រពាំងប្រិយ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៩៧គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិត្រពាំងប្រិយ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីសរុបទំហំ ១.៤១២ ហិកតា នៅស្រុកសំឡូត ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន រ័ត្នសម្បត្តិ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.000 គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១១ ឧបប ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១.៤១២ ហិកតា ក្នុងនោះ (១) ទំហំ ១.៤០០,៥ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និង (២) ទំហំ ១១,៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វត្តសម្បត្តិ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

- កាត់ផ្ទៃដីទំហំ ៤៩៦,៥ ហិកតា ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិចំការចេក
- កាត់ផ្ទៃដីទំហំ ៥៥៤,៥ ហិកតា ក្នុងនោះ (១) ទំហំ ៥៤៣ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុនភាពីម៉ិច និង (២) ទំហំ ១១,៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វត្តសម្បត្តិ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស៊ុង ១
- កាត់ផ្ទៃដីទំហំ ៣៦១ ហិកតា ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស៊ុង ២

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ១.០០០ គ្រួសារ នៅឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១៦ គ្រួសារ នៅភូមិចំការចេក
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៦៣ គ្រួសារ នៅភូមិស៊ុង១
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២២១ គ្រួសារ នៅភូមិស៊ុង២ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីសរុបទំហំ ៩.០៦៧ ហិកតា នៅស្រុករលាប្អៀរ ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្នុងនោះ កាត់ចេញពីដីអតីតសហគ្រាសសេរី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន គាពីម៉ិច និងកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤.៥៤៩ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសហគមន៍ និងជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្ដីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៩៧៣ លស ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៩.០៦៧ ហិកតា ក្នុងនោះ (១) ទំហំ ៦៣៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី (២) ទំហំ ៨.០១៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច និង (៣) ទំហំ ៤១៦ ហិកតា កាត់ចេញពីដីតម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ៨.៣៨៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៧៨ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១.ឃុំពង្រ ស្រុករលាប្អៀរ

- ផ្ទៃដីទំហំ ១២៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ១១១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៣ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងធំ ។
- ផ្ទៃដីទំហំ ១៦៤ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ១៤៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិថ្នារប ។

២.ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ

- ផ្ទៃដីទំហំ ២៥៥ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ២៤៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្វាយចេក ។
- ផ្ទៃដីទំហំ ៩២ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី សម្រាប់ប្រទានកម្មទំហំ ៨៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្វាយជ្រុំថ្មី ។

៣.ឃុំក្បាលទឹក ស្រុកទឹកផុស

- កាត់ផ្ទៃដីសរុបទំហំ ៩៨៩ ហិកតា ក្នុងនោះ (១) ទំហំ ៥៧៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច និង (២) ទំហំ ៤១៦ ហិកតា កាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ សម្រាប់ប្រទានកម្មទំហំ ៩២៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៤ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិខ្ទិតទួលឃ្លាំង

៤.ឃុំក្រាំងស្គារ ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៥.៨៥៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៥.៤៣១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤២២ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិអញ្ចាញ

៥.ឃុំចោងម៉ោង ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៣៧៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៣៣០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤៧ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិអលង្កែរ
- ផ្ទៃដីទំហំ ១២៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ១១០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៤ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងជុំ

៦.ឃុំទួលខ្ពស់ ស្រុកទឹកផុស

- ផ្ទៃដីទំហំ ៧០៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ៦៣៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៧ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងស្នាច់

៧.ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ

- ផ្ទៃដីទំហំ ១៦០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ១៥៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងទំលាប់ ។

- ផ្ទៃដីទំហំ ២២៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ប្រទានកម្មទំហំ ២០៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ១៧ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃញាម

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ១-ឧបសម្ព័ន្ធ៧ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៤.៥៤៩ គ្រួសារ និងទំហំ ៦៧៨ ហិកតា រក្សាទុកសម្រាប់សហគមន៍ព្រៃឈើ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១.ឃុំពង្រ ស្រុករលាប្អៀរ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៨ គ្រួសារ នៅភូមិត្រពាំងធំ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៦ គ្រួសារ នៅភូមិថ្នរាប ។

២.ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៥ គ្រួសារ នៅភូមិស្វាយចេក ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២៨ គ្រួសារ នៅភូមិស្វាយជ្រុំថ្មី ។

៣.ឃុំក្បាលទឹក ស្រុកទឹកផុស
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦២ គ្រួសារ នៅភូមិខ្ទិតទួលឃ្លាំង ។

៤.ឃុំក្រាំងស្គារ ស្រុកទឹកផុស
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៤៥ គ្រួសារ នៅភូមិអញ្ចាញ ។

៥.ឃុំចោងម៉ោង ស្រុកទឹកផុស
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៩៩ គ្រួសារ នៅភូមិអលង្គែរ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១៦ គ្រួសារ នៅភូមិត្រពាំងជុំ ។

៦.ឃុំទួលខ្ពស់ ស្រុកទឹកផុស
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧០ គ្រួសារ នៅភូមិត្រពាំងស្នាច់ ។

៧.ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩៣ គ្រួសារ នៅភូមិត្រពាំងទំលាប់ ។
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៧ គ្រួសារ នៅភូមិព្រៃញាម ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១.០០៧,៣៩ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពី (១) ដីតម្រូវព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Grands Timber LTD ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៥៣អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ១.០០៧,៣៩ហិកតា ក្នុងនោះ (១) ទំហំ ១០៧,៨៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ ៨៩៩,៥០ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Grands Timber LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៧៥៥,១០ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២៥២,២៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិដូង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ទី២ ទី៣ ទី៤ និងទី៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣២៥គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិដូង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៧៩៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៤៩៤,៦៧ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពី (១) ដីគម្របព្រៃឈើ ឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Grands Timber LTD ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៩១ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៥៩អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៤៩៤,៦៧ ហិកតា ក្នុងនោះ (១) ទំហំ ២៣២,១៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ ២៦២,៤៨ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Grands' Timber LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៤៧២,០៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២២,៦៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃទទឹង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមានទីតាំងដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ទី២ និងទី៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២១៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃទទឹង ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីទំហំ ២.៤២២ ហិកតា នៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចេញពីដីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧២៩ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦៧៨ ខបប ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃដីទំហំ ២.៤២២ ហិកតា ចេញពីដីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧២៩ គ្រួសារ នៅឃុំរស្មីសង្ហារ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលក្នុងនោះរួមមាន ៖

- កាត់ផ្ទៃដីទំហំ ៨៣៩,៥ ហិកតា ចេញពីដីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិនាងលេម
- កាត់ផ្ទៃដីទំហំ ៤០៥ ហិកតា ចេញពីដីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអណ្តើកដប់មួយ
- កាត់ផ្ទៃដីទំហំ ៦២៨,៥ ហិកតា ចេញពីដីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិពេជ្រចង្វារ។
- កាត់ផ្ទៃដីទំហំ ៥៤៩ ហិកតា ចេញពីដីព្រៃសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិបាដាកជើង។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៧២៩ គ្រួសារ នៅឃុំរស្មីសង្ហារ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលក្នុងនោះរួមមាន ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧០ គ្រួសារ នៅភូមិនាងលេម
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៦២ គ្រួសារ នៅភូមិអណ្តើកដប់មួយ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣៧ គ្រួសារ នៅភូមិពេជ្រចង្វារ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៦០ គ្រួសារ នៅភូមិបាដាកជើង ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៩៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ៤៤១,៦៤ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពី (១) ដីគម្រប ព្រៃឈើឆ្នាំ ២០០២ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Grands Timber LTD ដើម្បី ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៥២អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៨៤១,៦៤ ហិកតា ក្នុងនោះ (១) ទំហំ ២២៤,៨៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ២១៦,៧៥ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Grands Timber LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៥១៦,១៩ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២៥,៤៥ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃកាហៀច ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ និងទី២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២១០គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃកាហៀច ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១.៤៧៣,៧៤ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៤៨៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៥០អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ១.៤៧៣,៧៤ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ១.៤១២,០៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៦១,៦៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិក្រាំងធំ ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៨៨៥គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិក្រាំងធំ ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ដំឡើងឋានន្តរសក្តិថ្នាក់វរនាវីឯក**

១-វរនាវីទោ **ហុង ម៉ុន** អត្តលេខ ០៥៥៨៩១ នាយ ការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងទ័ពជើងទឹក

២-វរនាវីទោ **អ៊ិន សុខេមរ៉ា** អត្តលេខ ០៣១០០៨ មេបញ្ជាការ កងនាវាល្បាតឆ្នេរ៦ មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក

៣-វរនាវីទោ **សួង វ៉ាឌុច** អត្តលេខ ០៣១០៩៣ មេបញ្ជាការ កងនាវាប្រដេញ៧ មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក

៤-វរនាវីទោ **សំ សារឿន** អត្តលេខ ០១១៣៥៩ នាយសេនាធិការរង កងពលតូចការពារ កោះឆ្នេរលេខ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក

៥-វរនាវីទោ **ស៊ូ ចន្ថារី** អត្តលេខ ០១៥៤៦៤ នាយសេនាធិការរង កងពលតូចការពារ កោះឆ្នេរលេខ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក

៦-វរនាវីទោ **នុត សារ៉ាឌុច** អត្តលេខ ០១៥៦៩៥ នាយសេនាធិការរង កងពលតូចការពារ កោះឆ្នេរលេខ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក

**ខ-ដំឡើងឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯក**

១-វរសេនីយ៍ទោ **ជា សារិន** អត្តលេខ ០២៧៩២២ នាយលេខាធិការដ្ឋាន យោធភូមិភាគទី១

២-វរសេនីយ៍ទោ **ហួត រិទ្ធ** អត្តលេខ ០៣៦៦៥១ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងមណ្ឌលគីរី

៣-វរសេនីយ៍ទោ **ខឹម នៃ** អត្តលេខ ០២២៦៧០ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងព្រះវិហារ

៤-វរសេនីយ៍ទោ **ធឹម សាឌុច** អត្តលេខ ០១០១៦៤ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងសៀមរាប

៥-វរសេនីយ៍ទោ **ជួន នាង** អត្តលេខ ០០២៧៩៧ មេបញ្ជាការតំបន់អភិវឌ្ឍន៍ យោធភូមិភាគទី៣

៦-វរសេនីយ៍ទោ **ឃឹម សុគន្ធ** អត្តលេខ ០១៥៤០២ នាយ ការិយាល័យសុខាភិបាល យោធភូមិភាគទី៣

៧-វរសេនីយ៍ទោ **មាស សារឿន** អត្តលេខ ០០២៨០៦ នាយ ការិយាល័យបញ្ជូនសារ យោធភូមិភាគទី៣

៨-វរសេនីយ៍ទោ **មាស សាផន** អត្តលេខ ០១០៤៣៦ នាយ ការិយាល័យបំភ័ន្តអក្ខរៈ យោធភូមិភាគទី៣

៩-វរសេនីយ៍ទោ **ជុច សាឃន** អត្តលេខ ០១០៥៨១ នាយ ការិយាល័យកាំភ្លើងធំ យោធភូមិភាគទី៣

១០-វរសេនីយ៍ទោ **អ៊ួន សារុំ** អត្តលេខ ០០២៨០៧ នាយការិយាល័យវិស្វកម្ម យោធភូមិភាគទី៣

១១-វរសេនីយ៍ទោ **អ៊ុង ដេម៉ូ** អត្តលេខ ០២៣៣៣៧ ជំនួយការ ឯកឧត្តម សេង សុង មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១២-វរសេនីយ៍ទោ **នៃ ស៊ីដា** អត្តលេខ ០២៥៧៧៤ នាយទាហាន ប្រចាំគណៈបញ្ជាការឯកភាព សមរភូមិទិសយោធភូមិភាគទី៣ បញ្ជាការដ្ឋានកងទ័ពជើងគោក

១៣-វរសេនីយ៍ទោ **អ៊ុក ប៊ុនធឿន** អត្តលេខ ០១៦៤៦៤ នាយទាហាន ប្រចាំគណៈបញ្ជាការឯកភាព សមរភូមិទិសទី៣ យោធភូមិភាគទី៤ បញ្ជាការដ្ឋានកងទ័ពជើងគោក

១៤-វរសេនីយ៍ទោ **ហោង នីតា** អត្តលេខ ០១៤៦៩០ នាយទាហាន ប្រចាំគណៈបញ្ជាការឯកភាព សមរភូមិ យោធភូមិភាគទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

១៥-វរសេនីយ៍ទោ **សួស ច័ន្ទធឿន** អត្តលេខ ០០៨៩៣៦ នាយទាហាន ប្រចាំគណៈបញ្ជាការឯកភាព សមរភូមិទិស យោធភូមិភាគទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

១៦-វរសេនីយ៍ទោ **មាស ឿន** អត្តលេខ ០០៩៤៤១ នាយទាហាន ប្រចាំគណៈបញ្ជាការឯកភាព សមរភូមិទិសយោធភូមិភាគទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

១៧-វរសេនីយ៍ទោ **ឈុន ម៉ៅ** អត្តលេខ ០១២៧២៩ នាយទាហាន ប្រចាំទិសទី១ យោធភូមិភាគទី៥

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង បណ្តាសមាសភាព ដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៩០.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

# សម្រេច

**មាត្រា ១ :** ប្តូរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការចំនួន ២៦ រូប តាមរយៈការប្រឡងប្រជែងប្តូរប្រភេទក្របខ័ណ្ឌរបស់មន្ត្រីរាជការស៊ីវិល នៃក្រសួងពាណិជ្ជកម្ម ពីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ទៅក្នុងឋានន្តរសក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ និងទៅក្នុងឋានន្តរសក្តិមន្ត្រីបច្ចេកទេសមធ្យម នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ក្របខ័ណ្ឌចាស់ | ក្របខ័ណ្ឌថ្មី |
|---|---|---|---|---|---|
| **ក្របខ័ណ្ឌមន្ត្រីក្រមការ** | | | | | |
| ១ | **សួន សារឿន** | ប | 25-03-67 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៤ | ក្រមការ ថ្នាក់លេខ១៤ |
| ២ | **ឧស់ ស៊ីណា** | ប | 26-12-60 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៨ | ក្រមការ ថ្នាក់លេខ១៤ |
| ៣ | **ទេព ណារ៉ា** | ស | 19-05-62 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៤ | ក្រមការ ថ្នាក់លេខ១៤ |
| ៤ | **ថេង ទីសាខ៉ាន់ណៃ** | ស | 01-10-57 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៥ | ក្រមការ ថ្នាក់លេខ១៤ |
| ៥ | **ណុប សុម៉ារ៉ា** | ស | 25-06-60 | លេខាធិការរដ្ឋបាល ថ្នាក់លេខ១០ | ក្រមការ ថ្នាក់លេខ១៤ |
| ៦ | **សេង ស្រឿង** | ប | 01-07-58 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៧ | ក្រមការ ថ្នាក់លេខ១៤ |
| ៧ | **មៀច ចន្ធូរី** | ស | 02-02-70 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៩ | ក្រមការ ថ្នាក់លេខ១៤ |
| ៨ | **នៃ លីមត្រី** | ប | 03-02-69 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៨ | ក្រមការ ថ្នាក់លេខ១៤ |
| ៩ | **អោម ម៉ិនធឿន** | ប | 01-01-69 | លេខាធិការរដ្ឋបាល ថ្នាក់លេខ៩ | ក្រមការ ថ្នាក់លេខ១៤ |
| ១០ | **ស៊ិន សិទ្ធារី** | ស | 20-04-71 | លេខាធិការរដ្ឋបាល ថ្នាក់លេខ១០ | ក្រមការ ថ្នាក់លេខ១៤ |
| ១១ | **ហ៊ិន ឫទ្ធី** | ប | 15-03-67 | លេខាធិការរដ្ឋបាល ថ្នាក់លេខ១១ | ក្រមការ ថ្នាក់លេខ១៤ |
| ១២ | **ឃី សោផល** | ស | 26-02-60 | ភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ៣ | ក្រមការ ថ្នាក់លេខ១៤ |
| ១៣ | **ចេម សារឿន** | ស | 25-10-68 | ភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ៤ | ក្រមការ ថ្នាក់លេខ១៤ |
| **ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម** | | | | | |
| ១៤ | **ចាន់ ណារឿន** | ប | 10-06-58 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ១៥ | **តាំង សុគន្ធមាលា** | ស | 15-06-68 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ១៦ | **អៀន សេរីឧត្តម** | ប | 13-02-62 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ១៧ | **យាន យ៉ុង** | ប | 07-10-70 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ១៨ | **រាជ រតនី** | ស | 14-04-71 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ១៩ | **គួច យាងទី** | ប | 10-08-73 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ២០ | **សុខ មុនី** | ស | 21-05-65 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ២១ | **ខាង មុនី** | ប | 10-09-70 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ២២ | **គួយ សៀកលីម** | ប | 05-10-69 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៨ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |

| | | | | | |
|---|---|---|---|---|---|
| ២៣ | **ឈុន ស៊ីន** | ប | 13-11-74 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៨ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ២៤ | **ពេជ្រ ចិន្តា** | ប | 05-04-68 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៨ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ២៥ | **យ៉ុង សុទ្ធី** | ប | 20-01-72 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |
| ២៦ | **ម៉ា សុធី** | ប | 21-09-58 | មន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ១០ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ១៤ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៧៩១ . អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលចំនួន ០៩ រូប របស់ក្រសួងចំនួន ០២ ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| **ក្រសួងធនធានទឹក និងឧតុនិយម** (**អាជ្ញាធរទន្លេសាប**) | | | | |
| ១ | **អ៊ឹង គីមលាង** | ប | ពីអនុមន្ត្រី ថ្នាក់លេខ **៩** | ទៅវរមន្ត្រី ថ្នាក់លេខ **១០** |

| | | | | |
|---|---|---|---|---|
| ២ | **ខុម មាស** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| **ក្រសួងព័ត៌មាន** | | | | |
| ១ | **កង សុវណ្ណា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២ | **សាន ពុទ្ធារី** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៣ | **ជា សុខេន** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៤ | **ហោ សុភាព** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៥ | **សូ សុត្ថា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៦ | **ខាន់ សុភីរម្យ** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |
| ៧ | **ជួន ចាន់តារុណា** | ប | ពីអនុមន្ត្រី ថ្នាក់លេខ ១១ | ទៅវរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ :** ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលចំនួន ០២ រូប របស់ក្រសួងសុខាភិបាល ពីឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ ទៅឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **ថុង ម៉េងឡុង** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ |
| ២ | **វ៉ា សាវ៉ន** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ |

**មាត្រា ៣ :** ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលចំនួន ០៥ រូប របស់ក្រសួងអប់រំ យុវជន និងកីឡា ពីឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម ទៅឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **ជ័យ សារិន** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៦ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើម ខ្សែ ថ្នាក់លេខ ៧ |
| ២ | **អាម់ យាង** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើម ខ្សែ ថ្នាក់លេខ ៩ |
| ៣ | **ហ៊ីត ស៊ីអាត** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើម ខ្សែថ្នាក់លេខ ៩ |
| ៤ | **សុខ ឫទ្ធី** | ប | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើម ខ្សែថ្នាក់លេខ ១០ |
| ៥ | **អ៊ឹង រ៉ាមី** | ស | ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១ | ទៅគ្រូបង្រៀនកម្រិតឧត្តមដើម ខ្សែថ្នាក់លេខ ១០ |

**មាត្រា ៤ :** ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ១២ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

របស់ក្រសួងចំនួន ០៣ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ ត្រូវដំឡើង |
|---|---|---|---|---|
| **ក្រសួងព័ត៌មាន** | | | | |
| ១ | **ម៉ែន សាម៉ន** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | |
| ១ | **ឈី សុខា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ២ | **អ៊ិច សុខុម** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ៣ | **ទេព ម៉ិន្លា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៤ | **ប៉ុក សុផាត** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៥ | **លិប លឿង** | ស | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ៦ | **ចែម សង្វារ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៧ | **ឡាយ ម៉ារីទ៊ុ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ៨ | **រស់ សុរត្នា** | ស | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ៩ | **ឡេ ម៉ាយភឿង** | ស | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧ |
| ១០ | **ម៉ៅ ផល្លា** | ប | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| **ក្រសួងធនធានទឹក និងឧតុនិយម(អាជ្ញាធរទន្លេសាប)** | | | | |
| ១ | **ហៃល តូនី** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |

**មាត្រា ៥ :** ដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ៣៧ រូប ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ ត្រូវដំឡើង |
|---|---|---|---|---|
| ១ | **ជួន ចន្ថោភាស** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២ | **កែវ គៀតតូហ្វ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣ | **អឹត ម៉ុនគី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៤ | **ឯក សុទ្ធាឫទ្ធិ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧ |
| ៥ | **សាង សុខុម** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៦ | **គីម ចាន់មុនីឌ្ឋ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |

| | | | | |
|---|---|---|---|---|
| ៧ | **ខូន ផល្លា** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៨ | **ឈិត សុផល** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៩ | **ពៅ ម៉ុនធឿន** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១០ | **កើត ឈុនលី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១១ | **ចក ធីតា** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១២ | **សាំង សាលី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៣ | **អោ អ៊ុច** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១៤ | **គង់ សន្យា** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១៥ | **សារ៉ាក់ ផល្លី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១៦ | **សៀង សុម៉ាដេត** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៧ | **ជា សាធុជ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ១៨ | **សុខ ម៉ុនថា** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ១៩ | **ជឹង ប្រាមោទ្យ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២០ | **សុខ បូរី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២១ | **តួ ស៊ុយ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២២ | **សំ សមានា** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២៣ | **ឡេង លាប** | ស | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |

| | | | | |
|---|---|---|---|---|
| ២៤ | **ហួត សេង** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ២៥ | **ឈរ ណារ៉េត** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២៦ | **ទីវ៉េត សុឫទ្ធី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២៧ | **អ៊ុង ចក្រាវុធ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២៨ | **ច័ន្ទ សំឡេង** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ២៩ | **ដួង ឆាយ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣០ | **ខូ សុភៈស្មី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣១ | **គោគ សុវណ្ណា** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣២ | **គិន វណ្ណា** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣៣ | **ម៉ម ប៊ុនសុជាតិ** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣៤ | **ស៊ិន ប៉ូលី** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ |
| ៣៥ | **ថាន់ សុវណ្ណដេត** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣៦ | **សំ សទ្ធាត** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |
| ៣៧ | **តែ វ៉ាន់ថា** | ប | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨ |

**មាត្រា ៦ :** ដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០៤ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ចំនួន ០៣ ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ ត្រូវដំឡើង |
|---|---|---|---|---|
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | | | | |
| ១ | **ថោង ពោជ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៩ |
| ២ | **លឹម គង់** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |

| | | | | |
|---|---|---|---|---|
| **ក្រសួងព័ត៌មាន** | | | | |
| ១ | **ស៊ី ច័ន្ទតារា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | | |
| ១ | **វង្ស ម៉ុនឥន្ទ្រាវុធ** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៧ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៩៣ អនក្រ.ចស

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីអនុក្រឹត្យថ្មី ឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់អនុក្រឹត្យចាស់)

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង... (ឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំ) រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

**(គោរមងារនិងឈ្មោះ)**

បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួង**...ឬ **រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័នសាមី)

(ហត្ថលេខា)

**(ឈ្មោះ)**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា... (ពាក់ព័ន្ធក្រសួង ស្ថាប័នដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**៣.២.៧.៣- ទម្រង់នៃសេចក្ដីសម្រេច**

សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ជាលិខិតបទដ្ឋានគតិយុត្តមានទម្រង់ និងខ្លឹមសារជាចំណាត់ការរបស់រាជរដ្ឋាភិបាល ដែលប្រើចំពោះការងារមានវិសាលភាពនិងលក្ខណៈមិនស្ថិតស្ថេរយូរអង្វែង។

លិខិតបទដ្ឋានគតិយុត្តនេះ មាននាទីចែងជាអាទិ៍ពីការផ្ទេរសិទ្ធិ ការតែងតាំងឬការប្រគល់ភារកិច្ចជូនសមាជិករាជរដ្ឋាភិបាល ការបង្កើតគណៈកម្មការ អនុគណៈកម្មការ ក្រុមការងារ ការតែងតាំងសមាសភាពរបស់ក្រុមប្រឹក្សាជាតិឬអាជ្ញាធរជាតិឬគណៈកម្មាធិការជាតិ ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យហើយក្នុងនោះមានចែងតែតួនាទីរបស់សមាសភាព ដោយមិនដាក់ឈ្មោះ។

ទម្រង់នៃសេចក្ដីសម្រេចចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ដែលមានសញ្ញាជាតិ (ដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)នៅខាងលើចំកណ្ដាលទំព័រ ក្រោមសញ្ញាជាតិ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ប៉ែកខាងឆ្វេងស្មើនឹងបន្ទាត់បាវចនា ត្រូវដាក់ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោមរាជរដ្ឋាភិបាលកម្ពុជា ដាក់ពាក្យ **លេខ** :... សម្រាប់ទុកចុះលេខរបស់សេចក្ដីសម្រេចដែលមានរូបមន្តអក្សរកាត់ **លេខ** :... ស.សរ.។

នៅក្រោមបាវចនារំលង១បន្ទាត់ ចំកណ្ដាលទំព័រ ត្រូវដាក់ពាក្យ **សេចក្ដីសម្រេច** ក្រោមពាក្យសេចក្ដីសម្រេច ដាក់ពាក្យ **ស្ដីពី** ក្រោមពាក្យ ស្ដីពី ដាក់ចំណងជើងនៃសេចក្ដីសម្រេច។

នៅក្រោមចំណងជើង ចំកណ្ដាលរំលង១បន្ទាត់ ត្រូវដាក់ **រាជរដ្ឋាភិបាល**។

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្ដីសម្រេច ហើយសរសេរដោយប្រើពាក្យ បានឃើញ។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងសេចក្ដីសម្រេចមានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្ដីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្ដី ដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ... (ឬប្រធានស្ថាប័នសាមី)។

ជាគោលការណ៍សេចក្ដីសម្រេចមិនមានយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោម ចំកណ្ដាលទំព័រ ត្រូវសរសេរពាក្យ៖

**សម្រេច**

គ- ខ្លឹមសារនៃអត្ថបទ ត្រូវប្រើពាក្យ **ប្រការ** មិនប្រើពាក្យ **មាត្រា** ដូចក្នុងអនុក្រឹត្យទេ។ ប្រការស្ដង់ដានៃសេចក្ដីសម្រេច អាចចែងពីការនិរាករបទប្បញ្ញត្តិនៃសេចក្ដីសម្រេចចាស់គ្រង់ប្រការណាមួយឬទាំងស្រុងឬលិខិតបទដ្ឋានគតិយុត្តណាមួយដែលមានឋានានុក្រមស្មើឬទាបជាង។ ប្រការបញ្ចប់ត្រូវចែងពីការប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំឬស្នើ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដែលត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឃ- រូបមន្តបញ្ចប់ នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែង កាលបរិច្ឆេទ ហត្ថលេខាគោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រីស្តីទី និងបោះត្រារបស់រាជរដ្ឋាភិបាល។ សេចក្តីសម្រេចមិនមានហត្ថលេខាអមទេ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី ដូចប្រការ...(ពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន និងសាមីជនដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការផ្ទេរសិទ្ធិ នៅទំព័រទី៩៥និង៩៦ និងគំរូទម្រង់នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការ នៅទំព័រទី៩៧និង៩៨។

គំរូទម្រង់នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការផ្ទេរសិទ្ធិ

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...

## សេចក្តីសម្រេច

## ស្តីពី

(ចំណងជើងជាអក្សរមូល)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ...(ឈ្មោះ) ...(មុខតំណែង) ជា...(មុខតំណែង)ស្តីទី ជំនួស...(ឈ្មោះ) ...(មុខតំណែង) ដែលត្រូវអញ្ជើញទៅ...(កម្មវត្ថុបេសកកម្ម) នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... រហូតដល់ពេលឯកឧត្តម...(ឈ្មោះ) ...(មុខតំណែង) អញ្ជើញនិវត្តមកកាន់មាតុប្រទេសវិញ។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

**(គោរមងារនិងឈ្មោះ)**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ... (ពាក់ព័ន្ធក្រសួង ស្ថាប័ន និងសាមីជនដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

គំរូទម្រង់នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការ

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...

## សេចក្តីសម្រេច

## ស្តីពី

(ចំណងជើងជាអក្សរមូល)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ...ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ )
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ស.សរ. ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី)

# សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការ... ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម ...(ឈ្មោះ) ...(មុខតំណែង) ប្រធាន

២- ឯកឧត្តម ...(ឈ្មោះ) ...(មុខតំណែង) អនុប្រធាន

៣- ...។

**ប្រការ២ .-**

គណៈកម្មការនេះមានភារកិច្ច ............................................................................................................................................ និងធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី។ ឬ

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ...
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣ .-**

............................................................................................................................................................................................................................................................................................................។

**ប្រការ... .-**

សេចក្ដីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករសេចក្ដីសម្រេចចាស់ទាំងស្រុង) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីសេចក្ដីសម្រេចថ្មីឬក្នុងករណីនិរាករផ្នែកមួយចំនួនរបស់សេចក្ដីសម្រេចចាស់)

**ប្រការ... .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង... (ឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំ) រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិងឈ្មោះ**)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ... (ពាក់ព័ន្ធក្រសួង ស្ថាប័ន និងសាមីជនដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៩៨/១៣០

**៣.២.៧.៤- ទម្រង់នៃសារាចរ**

ជាទូទៅ សារាចរជាលិខិតបទដ្ឋានគតិយុត្តដែលបញ្ជាក់បំភ្លឺចំណុចខ្លឹមសារជាលក្ខណៈច្បាប់ ពន្យល់បកស្រាយលិខិតបទដ្ឋានគតិយុត្តដែលមានលំដាប់ថ្នាក់ខ្ពស់ជាងឬលើកឡើងនូវវិធានការណែនាំសកម្មភាពការងារ ដើម្បីឱ្យអង្គភាពឬមន្ត្រីរាជការថ្នាក់ក្រោមអនុវត្ត។ សារាចររបស់រាជរដ្ឋាភិបាលជាលិខិតបទដ្ឋានគតិយុត្តចេញដោយប្រមុខរាជរដ្ឋាភិបាល សម្រាប់ណែនាំឱ្យក្រសួង ស្ថាប័ន និងរាជធានី ខេត្តអនុវត្ត។

សារាចររបស់រាជរដ្ឋាភិបាលមិនប្រើមូលបទនិងមាត្រាឬប្រការទេ ហើយមានទម្រង់ចែកចេញជា ៣ផ្នែក មានក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ដែលមានសញ្ញាជាតិ (ដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)នៅខាងលើចំកណ្តាលទំព័រ ក្រោមសញ្ញាជាតិ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ប៉ែកខាងឆ្វេងស្មើនឹងបន្ទាត់បាវចនា ត្រូវដាក់ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោម រាជរដ្ឋាភិបាលកម្ពុជា ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សារាចរដែលមានរូបមន្តអក្សរកាត់ **លេខ** : ... ស.រ.។

នៅក្រោមបាវចនា រំលង១បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សារាចរ** ក្រោមពាក្យ សារាចរ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃសារាចរ។

ខ- ខ្លឹមសារនៃអត្ថបទ

ខ.១- **សេចក្តីផ្តើម** ត្រូវយោងទៅរកលិខិតបទដ្ឋានគតិយុត្តដែលត្រូវវិភាគនិងពន្យល់បកស្រាយបញ្ជាក់ខ្លឹមសារឱ្យបានច្បាស់ឬត្រូវបង្ហាញអំពីបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្តដើម្បីឱ្យការអនុវត្តទទួលបានលទ្ធផលល្អ។

ខ.២- **តួសេចក្តី** ត្រូវចែងអំពីខ្លឹមសារដែលត្រូវបំភ្លឺនិងបកស្រាយឬបណ្តាវិធានការដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់តាមផ្លូវច្បាប់។

ខ.៣- **អវសានបទ** ត្រូវចែងថា ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត(តាមករណីពាក់ព័ន្ធ) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់(ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ)។

គ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែង កាលបរិច្ឆេទ ហត្ថលេខា គោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រីស្តីទីនិងត្រារបស់រាជរដ្ឋាភិបាល។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះស្ថាប័នសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត ដែលរួមមានក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត រាជកិច្ច និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃសារាចររបស់រាជរដ្ឋាភិបាល នៅទំព័រទី១០០។

គំរូទម្រង់នៃសារាចររបស់រាជរដ្ឋាភិបាល

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...

## សារាចរ

## ស្តីពី

(ចំណងជើងជាអក្សរមូល)

(សេចក្តីផ្តើម)

កន្លងមកទោះមានច្បាប់(ឬលិខិតបទដ្ឋានគតិយុត្ត) ស្តីពី...ក៏ដោយ ក៏រាជរដ្ឋាភិបាលសង្កេតឃើញថា...។

(តួសេចក្តី)

(គោលបំណង)ក្នុងករណីនេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការដូចខាងក្រោម៖

(ខ្លឹមសារណែនាំ) ១ - ...។

២ - ...។

(អវសានបទ)

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត(តាមករណីពាក់ព័ន្ធ) ត្រូវ (ផ្សព្វផ្សាយ) អនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ (ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិងឈ្មោះ**)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### ៣.២.៨- ទម្រង់នៃប្រកាស ប្រកាសអន្តរក្រសួង សេចក្តីសម្រេច សារាចរ និង សារាចរអន្តរក្រសួងរបស់ក្រសួង ស្ថាប័ន

#### ៣.២.៨.១- ទម្រង់នៃប្រកាស

ប្រកាស ជាលិខិតបទដ្ឋានគតិយុត្តចេញដោយរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន មានវិសាលភាពគ្របដណ្តប់លើវិស័យដែលក្រសួង ស្ថាប័ននោះទទួលបន្ទុក។ ប្រកាសមានពីរប្រភេទគឺ ប្រកាសមានលក្ខណៈជាបទបញ្ញាទូទៅនិងប្រកាសមានលក្ខណៈជាឯកត្តភូត។

ប្រកាសមានលក្ខណៈជាបទបញ្ញាទូទៅ ជាការណែនាំការអនុវត្តឬបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ជាការណែនាំការអនុវត្តកិច្ចការដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ដូចជាប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះក្រសួង ស្ថាប័ន ប្រកាសស្តីពីវិធានការចាំបាច់មួយចំនួន សម្រាប់គ្រប់គ្រងការនាំចេញ ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាដើម។

ប្រកាសមានលក្ខណៈជាឯកត្តភូតជាប្រកាសដែលទាក់ទងឬសំដៅចំឈ្មោះបុគ្គល។ ប្រកាសប្រភេទនេះ មានដូចជាប្រកាសស្តីពីការជ្រើសរើសមន្ត្រីឱ្យចូលក្របខ័ណ្ឌនិងធ្វើកម្មសិក្សា ការចាត់ឱ្យមន្ត្រីធ្វើកម្មសិក្សាបន្ថែម ការលុបឈ្មោះមន្ត្រីកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្ទេរភារកិច្ច ការផ្លាស់មន្ត្រីរាជការ ការដំឡើងឋានន្តរសក្តិ ការបន្ថយឋានន្តរសក្តិ ការដំឡើងថ្នាក់ ការបន្ថយថ្នាក់ ការដកពីមុខតំណែង ការអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការអនុញ្ញាតឬការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតឱ្យចូលបម្រើការងារឡើងវិញ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលនិវត្តន៍ ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌប្រភេទ គនិងឃ ការជ្រើសរើសបុគ្គលិកអណ្តែតឬមន្ត្រីជាប់កិច្ចសន្យាជាដើម។

ទម្រង់នៃប្រកាសចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដែលរៀបចំ ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័ន ក្រោមសញ្ញាដាក់ឈ្មោះក្រសួង ស្ថាប័ន ក្រោមឈ្មោះ ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់ប្រកាសដែលមានរូបមន្តអក្សរកាត់ **លេខ** : ... ប្រក. ...(អក្សរកាត់របស់ក្រសួង ស្ថាប័ន)។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **ប្រកាស** ក្រោមពាក្យ ប្រកាស ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃប្រកាស។

នៅក្រោមចំណងជើង ចំកណ្តាលរំលង១បន្ទាត់ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង** ...ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ **ប្រធានស្ថាប័ន**)។

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃប្រកាស ហើយសរសេរដោយប្រើពាក្យ បានឃើញ។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងប្រកាសមានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័នដែលរៀបចំប្រកាស អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នដែលរៀបចំប្រកាស ហើយនៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តីដោយថែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ

- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន ... (ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)។

ជាគោលការណ៍ ប្រកាសមិនមានយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោមចំកណ្តាលទំព័រ ត្រូវសរសេរពាក្យៈ

**សម្រេច**

គ- ខ្លឹមសារនៃអត្ថបទ អាចចែកជាជំពូក និងត្រូវប្រើពាក្យ **ប្រការ** ដោយមិនត្រូវប្រើពាក្យ **មាត្រា** ឡើយ។ ជំពូកស្តីពីអវសានប្បញ្ញត្តិ ចែងពីការនិរាករលិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិណាដែលផ្ទុយនឹងប្រកាសនេះ។ ចំពោះប្រការបញ្ចប់ ត្រូវចែងពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន និងសាមីខ្លួនដែលត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឃ- រូបមន្តបញ្ចប់ នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃប្រកាស។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខា និងឈ្មោះរបស់ប្រធានស្ថាប័នឬប្រធានស្ថាប័នស្តីទី។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យ(គោរមងារ) នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី សាលារាជធានី ខេត្ត(បើចាំបាច់) ដូចប្រការ...(មន្ត្រីនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃប្រកាសមានលក្ខណៈជាបទបញ្ជាទូទៅ នៅទំព័រទី១០៣និង១០៤ និងគំរូទម្រង់នៃប្រកាសមានលក្ខណៈជាឯកត្តភូត នៅទំព័រទី១០៥ដល់១១២។

គំរូទម្រង់នៃប្រកាសមានលក្ខណៈជាបទបញ្ញាទូទៅ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង** : ... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** : ...

**ប្រកាស**
**ស្តីពី**
(ចំណងជើងជាអក្សរមូល)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**
**ឬរដ្ឋមន្ត្រីក្រសួង...(ឬ ប្រធានស្ថាប័ន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/... (លេខខែឆ្នាំ)/... (លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញប្រកាសលេខ... ប្រក. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)

## សម្រេច

**ប្រការ១ .-**

.......................................................................................................................................។

**ប្រការ២ .-**

.......................................................................................................................................។

**ប្រការ... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។
(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ... .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...)ប្រធានមន្ទីរ... រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ
**រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**
(ហត្ថលេខានិងត្រា)
(**ឈ្មោះ**)

**កន្លែងទទួល :**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ...
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

គំរូទម្រង់នៃប្រកាសមានលក្ខណៈជាឯកត្តភូត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង** :... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** :...

**ប្រកាស**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**
**ឬរដ្ឋមន្ត្រីក្រសួង...(ឬ ប្រធានស្ថាប័ន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីលក្ខន្តិកៈដោយឡែកនៃ...(ឈ្មោះក្របខ័ណ្ឌរបស់មន្ត្រីសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញប្រកាសលេខ... ប្រក. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)

# សម្រេច

**ប្រការ១ ._**

**ចំពោះប្រកាសស្តីពីការជ្រើសរើសមន្ត្រីឱ្យចូលក្របខ័ណ្ឌនិងធ្វើកម្មសិក្សា ត្រូវចែងដូចតទៅ៖**

ត្រូវបានជ្រើសរើសលោក ... ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយត្រូវធ្វើកម្មសិក្សារយៈពេល...ខែ។ ឬ

ត្រូវបានជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌ... នៅ... ដោយត្រូវធ្វើកម្មសិក្សារយៈពេល ...ខែ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ...។

២- លោក ...។

**ចំពោះប្រកាសស្តីពីការចាត់ឱ្យមន្ត្រីធ្វើកម្មសិក្សាបន្ថែម ត្រូវចែងដូចតទៅ៖**

ត្រូវបានចាត់ឱ្យលោក ... មន្ត្រីកម្មសិក្សាក្នុងក្របខ័ណ្ឌ... នៅ... ធ្វើកម្មសិក្សាបន្ថែមរយៈពេល...ខែ ដោយមូលហេតុ...។ ឬ

ត្រូវបានចាត់ឱ្យធ្វើកម្មសិក្សាបន្ថែមរយៈពេល...ខែ មន្ត្រីកម្មសិក្សាក្នុងក្របខ័ណ្ឌ... នៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... ដោយមូលហេតុ...។

២- លោក ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការលុបឈ្មោះមន្ត្រីកម្មសិក្សា ត្រូវចែងដូចតទៅ៖**

ត្រូវបានលុបឈ្មោះលោក ... មន្ត្រីកម្មសិក្សាចេញពីក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយមូលហេតុ...។ ឬ

ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... មន្ត្រីកម្មសិក្សា ដូចមានរាយនាមខាងក្រោម៖

១- លោក ... ដោយមូលហេតុ...។

២- លោក ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅ៖**

ត្រូវបានតាំងស៊ប់លោក ... អត្តលេខ...(បើមាន) ក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... ។

២- លោក ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... ។

**ចំពោះប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... នៅ... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះប្រកាសស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... នៅ... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា ... ជំនួសលោក ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា ... ជំនួសលោក ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការ ដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យ សម្រាប់ អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... នៅ... ។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា...។

**ចំពោះប្រកាសស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យសម្រាប់អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... នៅ...។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

**ចំពោះប្រកាសស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ(ផ្ទៃក្នុង) ត្រូវចែងដូចតទៅ៖**

ត្រូវបានផ្ទេរភារកិច្ចលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី... (មុខតំណែង) ទៅជា...(មុខតំណែង) នៅ...។ ឬ

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង)។

**ចំពោះប្រកាសស្តីពីការផ្លាស់មន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានផ្លាស់លោក ... អត្តលេខ...(បើមាន) ឋានន្តរស័ក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... បច្ចុប្បន្ននៅ ... ឱ្យទៅបម្រើការងារនៅ...។ ឬ

ត្រូវបានផ្លាស់មន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរស័ក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... បច្ចុប្បន្ននៅ... ឱ្យទៅបម្រើការងារនៅ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរស័ក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... បច្ចុប្បន្ននៅ... ឱ្យទៅបម្រើការងារនៅ...។

**ចំពោះប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងឋានន្តរស័ក្តិលោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... ទៅឋានន្តរស័ក្តិ ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ...។ ឬ

ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... ទៅឋានន្តរស័ក្តិ... ថ្នាក់លេខ... នៅ ...។

២- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... ទៅឋានន្តរស័ក្តិ... ថ្នាក់លេខ... នៅ ...។

**ចំពោះប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិកិត្តិយសជូនមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងឋានន្តរស័ក្តិកិត្តិយសជូនលោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... ទៅឋានន្តរស័ក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដែលបាន... (ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។ ឬ

ត្រូវបានដំឡើងឋានន្តរស័ក្តិកិត្តិយសជូនមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... ទៅឋានន្តរស័ក្តិ... ថ្នាក់លេខ... នៅ ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។

២- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... ទៅឋានន្តរស័ក្តិ... ថ្នាក់លេខ... នៅ ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។

**ចំពោះប្រកាសស្តីពីការបន្ថយឋានន្តរស័ក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបន្ថយឋានន្តរស័ក្តិលោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... មកឋានន្តរស័ក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានបន្ថយឋានន្តរស័ក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... មកឋានន្តរស័ក្តិ... ថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរស័ក្តិ... ថ្នាក់លេខ... មកឋានន្តរស័ក្តិ... ថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

ចំពោះប្រកាសស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការតាមវេនជ្រើសរើសនិងវេនអតីតភាព ត្រូវចែងដូចតទៅ៖

ត្រូវបានដំឡើងថ្នាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ...។ ឬ

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

ចំពោះប្រកាសស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការ ដែលទទួលបានសញ្ញាបត្រខ្ពស់ជាងការកំណត់ក្នុងក្របខ័ណ្ឌត្រូវចែងដូចតទៅ៖

ត្រូវបានដំឡើងថ្នាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព។ ឬ

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ...ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

ចំពោះប្រកាសស្តីពីការបន្ថយថ្នាក់មន្ត្រីរាជការ ត្រូវចែងដូចតទៅ៖

ត្រូវបានបន្ថយថ្នាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានបន្ថយថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

ចំពោះប្រកាសស្តីពីការដកមន្ត្រីរាជការពីមុខតំណែង ត្រូវចែងដូចតទៅ៖

ត្រូវបានដកលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចេញពីមុខតំណែង... ដោយមូលហេតុ... ។ ឬ

ត្រូវបានដកមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង... ដោយមូលហេតុ...។

ចំពោះប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖

ត្រូវបានអនុញ្ញាតឱ្យលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។



ចំពោះប្រកាសស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖

ត្រូវបានបញ្ចប់ភារកិច្ចលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ ... មុខតំណែង... នៅ... ឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ(បើជាមន្ត្រីមានក្របខ័ណ្ឌ)។ ឬ

ត្រូវបានបញ្ចប់ភារកិច្ចមន្ត្រីរាជការឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រីមានក្របខ័ណ្ឌ)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រីមានក្របខ័ណ្ឌ)។

**ចំពោះប្រកាសស្តីពីការលុបឈ្មោះឬបញ្ឈប់មន្ត្រីរាជការពីការងារ ត្រូវចែងដូចតទៅ៖**

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់មន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ត្រូវចែងដូចតទៅ៖**

ត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍មុនកំណត់(តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះប្រកាសស្តីពីសមាហរណកម្មមន្ត្រីរាជការក្នុងក្របខ័ណ្ឌប្រភេទ គ និង ឃ ត្រូវចែងដូចតទៅ៖**

ត្រូវបានធ្វើសមាហរណកម្មលោក ... ទៅក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ... (បើមាន) នៅ...។ ឬ

ត្រូវបានធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌ... នៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

២- លោក ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

**ចំពោះប្រកាសស្តីពីការជ្រើសរើសបុគ្គលិកអណ្តែតឬមន្ត្រីជាប់កិច្ចសន្យា ត្រូវចែងដូចតទៅ៖**

ត្រូវបានជ្រើសរើសលោក ... ឱ្យចូលបម្រើការងារជាបុគ្គលិកអណ្តែតឬមន្ត្រីជាប់កិច្ចសន្យានៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយទទួលប្រាក់កម្រៃចំនួន...រៀលក្នុងមួយខែ។ ឬ

ត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារជាបុគ្គលិកអណ្តែតឬមន្ត្រីជាប់កិច្ចសន្យាចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយទទួលប្រាក់កម្រៃចំនួន...រៀលក្នុងមួយខែ ដូចមានរាយនាមខាងក្រោម៖

១- លោក ... នៅ...។

២- លោក ... នៅ...។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ៣ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...) ប្រធានមន្ទីរ...រាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**)

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ...
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

៣.២.៤.២- **ទម្រង់នៃប្រកាសអន្តរក្រសួង**

ប្រកាសអន្តរក្រសួង ជាប្រកាសរួមដែលចែងពីការចាត់វិធានការដោះស្រាយបញ្ហារួម តម្រូវឱ្យមានការសហការដោះស្រាយឬចាត់វិធានការដោយក្រសួង ស្ថាប័ន២ឬ៣ ដើម្បីអនុវត្តបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នហត្ថលេខី។ ក្នុងករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នលើសពី៣ ត្រូវរៀបចំជាអនុក្រឹត្យ។

ដូចប្រកាសដែរ ប្រកាសអន្តរក្រសួងមានលក្ខណៈជាបទបញ្ជាទូទៅនិងជាឯកត្តភូត។

ទម្រង់នៃប្រកាសអន្តរក្រសួងចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដើម ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័នដើម ក្រោមសញ្ញាដាក់ឈ្មោះក្រសួង ស្ថាប័នដើមនៅប៉ែកខាងឆ្វេង និងដាក់ឈ្មោះក្រសួង ស្ថាប័នដែលចូលរួមនៅប៉ែកខាងស្តាំ (ក្នុងករណីមាន២)ឬនៅចំកណ្តាល និងនៅប៉ែកខាងស្តាំ ដោយផ្អែកទៅតាមទំហំសមត្ថកិច្ចពាក់ព័ន្ធ(ក្នុងករណីមាន៣)។ នៅក្រោមឈ្មោះក្រសួង ស្ថាប័នដើម ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់ប្រកាសអន្តរក្រសួងដែលមានរូបមន្តអក្សរកាត់ **លេខ** : ... ប្រក. ... (អក្សរកាត់របស់ក្រសួង ស្ថាប័នដើម)។ លេខប្រកាសអន្តរក្រសួងត្រូវយកលេខរបស់ក្រសួង ស្ថាប័នដើម។ ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធច្រើនជាងគេ ជាក្រសួង ស្ថាប័នដើមដែលត្រូវទទួលបន្ទុករៀបចំប្រកាសអន្តរក្រសួងនេះ។

នៅក្រោមបាវចនារំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **ប្រកាសអន្តរក្រសួង** ក្រោមពាក្យ ប្រកាសអន្តរក្រសួង ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃប្រកាសអន្តរក្រសួង។

នៅក្រោមចំណងជើង ចំកណ្តាលរំលង១បន្ទាត់ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) (ប្រធានស្ថាប័នទាំងអស់ដែលចេញប្រកាសអន្តរក្រសួងនេះ ដោយត្រូវដាក់ពីឆ្វេងទៅស្តាំតាមទំហំសមត្ថកិច្ចពាក់ព័ន្ធ)។

ខ- **មូលបទ** ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃប្រកាសអន្តរក្រសួង ហើយសរសេរដោយប្រើពាក្យ បានឃើញ។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងប្រកាសអន្តរក្រសួង មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័នដែលទទួលបន្ទុករៀបចំនិងចូលរួមរៀបចំប្រកាសអន្តរក្រសួង អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នដែលទទួលបន្ទុករៀបចំនិងចូលរួមរៀបចំប្រកាសអន្តរក្រសួង ហើយនៅចុងក្រោយបង្អស់នៃមូលបទត្រូវយោងតាមករណីនីមួយៗនៃសេចក្តីដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង...(ឈ្មោះក្រសួង ស្ថាប័នរៀបចំប្រកាសអន្តរក្រសួងនេះ) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង... (ឈ្មោះក្រសួង ស្ថាប័នសាមី)។

ជាគោលការណ៍ ប្រកាសអន្តរក្រសួងមិនមានយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោម ចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ៖

## សម្រេច

គ- ខ្លឹមសារនៃអត្ថបទ អាចចែកជាជំពូកនិងត្រូវប្រើពាក្យ **ប្រការ** ដោយមិនត្រូវប្រើពាក្យ **មាត្រា** ឡើយ។ ជំពូកស្តីពីអវសានប្បញ្ញត្តិ ចែងពីការនិរាករលិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ។ ចំពោះប្រការបញ្ចប់ត្រូវចែងពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នទាំងនេះ ដែលត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឃ- រូបមន្តបញ្ចប់ នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែង និងកាលបរិច្ឆេទនៃប្រកាសអន្តរក្រសួង។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ស្របតាមទីតាំងនៅក្បាលលិខិត ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខានិងឈ្មោះរបស់ប្រធានស្ថាប័នឬប្រធានស្ថាប័នស្តីទីទាំងនោះ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី សាលារាជធានី ខេត្ត(បើចាំបាច់) ដូចប្រការ...(មន្ត្រីនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

នាយកដ្ឋានរដ្ឋបាលនៃក្រសួង ស្ថាប័នដើម មានភារកិច្ចចុះលេខនិងកាលបរិច្ឆេទលើប្រកាសអន្តរក្រសួង ហើយបោះត្រារបស់ក្រសួង ស្ថាប័នទាំងអស់ដែលរៀបចំប្រកាសអន្តរក្រសួង នៅតាមជ្រុងរឹមខាងក្រោមលើគ្រប់សន្លឹកស្របតាមកន្លែងចុះហត្ថលេខារបស់ប្រធានស្ថាប័ននីមួយៗនៃប្រកាសអន្តរក្រសួង លើកលែងតែសន្លឹកទំព័រដែលមានហត្ថលេខារបស់ប្រធានស្ថាប័នសាមីនៃប្រកាសអន្តរក្រសួងនេះ។

សូមមើលគំរូទម្រង់នៃប្រកាសអន្តរក្រសួង នៅទំព័រទី១១៥និង១១៦។

គំរូទម្រង់នៃប្រកាសអន្តរក្រសួង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

(សញ្ញាក្រសួង ស្ថាប័នដើម)

**ក្រសួង** : ... (ឈ្មោះក្រសួង ស្ថាប័ន) **ក្រសួង...** **ក្រសួង...**

**លេខ** : ... (អក្សរកាត់របស់ក្រសួង ស្ថាប័នដើម)

# ប្រកាសអន្តរក្រសួង
# ស្តីពី

(ចំណងជើងជាអក្សរមូល)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នដើមដែលរៀបចំនិងព្រះរាជក្រមស្តីពីការបង្កើតស្ថាប័នផ្សេងទៀតដែលចូលរួមរៀបចំប្រកាសអន្តរក្រសួង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័នដើមដែលរៀបចំនិងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័នផ្សេងទៀតដែលចូលរួមរៀបចំប្រកាសអន្តរក្រសួង)
- បានឃើញអនុក្រឹត្យលេខ... អនក្រ. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង...(ឈ្មោះក្រសួងស្ថាប័នរៀបចំប្រកាសអន្តរក្រសួងនេះ)ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឈ្មោះក្រសួង ស្ថាប័នសាមី)

## សម្រេច

**ប្រការ១ .-**

.................................................................................................................................។

**ប្រការ២ .-**

.................................................................................................................................។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។
(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...)នៃក្រសួង...និងក្រសួង... ប្រធានមន្ទីរ... រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...**(ឬប្រធានស្ថាប័ន) | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬ រដ្ឋមន្ត្រីក្រសួង...**(ឬប្រធានស្ថាប័ន) | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...**(ឬប្រធានស្ថាប័ន) |
| (ហត្ថលេខានិងត្រា) | (ហត្ថលេខានិងត្រា ) | (ហត្ថលេខានិងត្រា ) |
| (**ឈ្មោះ**) | (**ឈ្មោះ**) | (**ឈ្មោះ**) |

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ...
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**៣.២.៨.៣- ទម្រង់នៃសេចក្តីសម្រេច**

សេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន ជាលិខិតបទដ្ឋានគតិយុត្តមានទម្រង់និងខ្លឹមសារជាចំណាត់ការរបស់ក្រសួង ស្ថាប័ន ដែលប្រើចំពោះការងារមានវិសាលភាពនិងលក្ខណៈមិនស្ថិតស្ថេរយូរអង្វែង។

ទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដែលរៀបចំ ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័ន ក្រោមសញ្ញា ដាក់ឈ្មោះក្រសួង ស្ថាប័ន ក្រោមឈ្មោះដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សេចក្តីសម្រេចដែលមានរូបមន្តអក្សរកាត់ **លេខ** : ... ស.ស.រ. ...(អក្សរកាត់របស់ក្រសួង ស្ថាប័ន)។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សេចក្តីសម្រេច** ក្រោមពាក្យសេចក្តីសម្រេច ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃសេចក្តីសម្រេច។

នៅក្រោមចំណងជើង ចំកណ្តាលរំលង១បន្ទាត់ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**)។

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្តី សម្រេច ហើយសរសេរដោយប្រើពាក្យ បានឃើញ។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងសេចក្តីសម្រេច មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័ន អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ហើយនៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តីដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន ... (ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)។

ជាគោលការណ៍សេចក្តីសម្រេចមិនមានយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោម ចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ៖

**សម្រេច**

គ- ខ្លឹមសារនៃអត្ថបទ ត្រូវប្រើពាក្យ **ប្រការ** ដោយមិនត្រូវប្រើពាក្យ **មាត្រា** ឡើយ។ ចំពោះប្រការបញ្ចប់ ត្រូវចែងពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន និងសាមីខ្លួន ដែលត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឃ- រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃសេចក្តីសម្រេច។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោមត្រូវទុកចន្លោះសម្រាប់ហត្ថលេខា និងឈ្មោះរបស់ប្រធានស្ថាប័នឬប្រធានស្ថាប័នស្តីទី។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដូចប្រការ...(មន្ត្រីនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន ដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន នៅទំព័រទី១១៩និង១២០។

គំរូទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)
**ក្រសួង** : ... (ឈ្មោះក្រសួង ស្ថាប័ន)
**លេខ** : ...

**សេចក្តីសម្រេច**
**ស្តីពី**
(ចំណងជើងជាអក្សរមូល)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**
**ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័នសាមី)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញប្រកាសលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការ... ដែលមានសមាសភាពដូចខាងក្រោម៖

១- លោក ...(ឈ្មោះ) ...(មុខតំណែង) ប្រធាន
២- លោក ...(ឈ្មោះ) ...(មុខតំណែង) អនុប្រធាន
៣- ...។

**ប្រការ២ .-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ...
- ...។

**ប្រការ៣ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...) និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ដូចប្រការ...
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

៣.២.៨.៤- ទម្រង់នៃសារាចរ

សារាចររបស់ក្រសួង ស្ថាប័ន ជាលិខិតបទដ្ឋានគតិយុត្តចេញដោយរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន សម្រាប់ណែនាំឱ្យថ្នាក់ក្រោមអនុវត្ត។ ទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័នចែកចេញជា៣ផ្នែក មានក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដែលរៀបចំ ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័ន ក្រោមសញ្ញាដាក់ឈ្មោះ ក្រសួង ស្ថាប័ន ក្រោមឈ្មោះដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សារាចរដែលមានរូបមន្តអក្សរកាត់ **លេខ** : ...ស.រ.។ នៅក្រោមបាវចនារំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សារាចរ** ក្រោមពាក្យ សារាចរ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃសារាចរ។

ខ- ខ្លឹមសារនៃអត្ថបទ

ខ.១- សេចក្តីផ្តើម ត្រូវយោងទៅរកលិខិតបទដ្ឋានគតិយុត្តដែលត្រូវវិភាគនិងពន្យល់ ដើម្បីបកស្រាយបញ្ជាក់ខ្លឹមសារឱ្យបានច្បាស់ឬត្រូវបង្ហាញអំពីបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្ត ដើម្បីឱ្យការអនុវត្តបន្តទទួលបានលទ្ធផលជាវិជ្ជមាន។

ខ.២- តួសេចក្តី ត្រូវចែងអំពីការកំណត់ខ្លឹមសារឬការបកស្រាយបញ្ហា ព្រមទាំងបណ្តាវិធានការដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់តាមផ្លូវច្បាប់។

ខ.៣- អវសានបទ ត្រូវចែងថាទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង (ឬស្ថាប័ន) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង (ឬស្ថាប័ន)វិញ។

គ- រូបមន្តបញ្ចប់ នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃសារាចរ។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខា និងឈ្មោះរបស់ប្រធានស្ថាប័នឬប្រធានស្ថាប័នស្តីទី។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះស្ថាប័ន អង្គភាពសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត មានជាអាទិ៍ ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យ (គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គនាយកដ្ឋាន នាយកដ្ឋាន សាលារាជធានី ខេត្ត មន្ទីរជំនាញរាជធានី ខេត្ត រាជកិច្ច និងឯកសារ កាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័ន នៅទំព័រទី១២២។

គំរូទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង** :... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** :...

# សារាចរ
## ស្តីពី
(ចំណងជើងជាអក្សរមូល)

(សេចក្តីផ្តើម)

កន្លងមក ក្រសួង (ឬស្ថាប័ន)បានសង្កេតឃើញថា ក្នុងការអនុវត្តអនុក្រឹត្យលេខ... ចុះថ្ងៃទី... ខែ ... ឆ្នាំ... ស្តីពី...ឬប្រកាសលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...ឬសារាចរលេខ...ចុះថ្ងៃទី ... ខែ... ឆ្នាំ... ស្តីពី... បានប្រទះការលំបាកជាច្រើន ...។

(តួសេចក្តី)

(គោលបំណង)ដើម្បីជៀសវាងការលំបាកទាំងនេះ ក្រសួង(ឬស្ថាប័ន) សូមធ្វើការណែនាំដូចខាងក្រោម៖

(ខ្លឹមសារណែនាំ) ១. - ... (រៀបរាប់ចំណុចដែលត្រូវណែនាំ)។

២. - ...។

(អវសានបទ)

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង(ឬស្ថាប័ន) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង(ឬស្ថាប័ន)វិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

(ហត្ថលេខានិងត្រា)

**(ឈ្មោះ)**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គនាយកដ្ឋាន
- នាយកដ្ឋាន
- សាលារាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### ៣.២.៨.៥- ទម្រង់នៃសារាចរអន្តរក្រសួង

សារាចរអន្តរក្រសួង ជាលិខិតបទដ្ឋានគតិយុត្តចេញដោយក្រសួង ស្ថាប័ន២ឬ៣ ដើម្បីណែនាំឱ្យថ្នាក់ក្រោមសហការអនុវត្ត។ ក្នុងករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នលើសពី៣ ត្រូវរៀបចំជាសារាចររបស់រាជរដ្ឋាភិបាល។

ទម្រង់នៃសារាចរអន្តរក្រសួងចែកចេញជា៣ផ្នែក មានក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដើម ដោយនៅផ្នែកខាងលើចំ កណ្តាលទំព័រ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័នដើម ក្រោមសញ្ញាដាក់ឈ្មោះក្រសួង ស្ថាប័នដើមនៅប៉ែកខាងឆ្វេង និងដាក់ឈ្មោះក្រសួង ស្ថាប័នដែលចូលរួមនៅប៉ែកខាងស្តាំ(ក្នុងករណីមាន២)ឬនៅចំកណ្តាល និងនៅប៉ែកខាងស្តាំ ដោយផ្អែកទៅតាមទំហំសមត្ថកិច្ចពាក់ព័ន្ធ(ក្នុងករណីមាន៣)។ នៅក្រោមឈ្មោះស្ថាប័នដើមដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សារាចរអន្តរក្រសួង ដែលមានរូបមន្តអក្សរកាត់ **លេខ** : ... ស.រ. (អក្សរកាត់របស់ក្រសួង ស្ថាប័នដើម)។ លេខសារាចរអន្តរក្រសួង ត្រូវយកលេខរបស់ក្រសួង ស្ថាប័នដើម។ ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធច្រើនជាងគេ ជាក្រសួង ស្ថាប័នដើមដែលត្រូវទទួលបន្ទុករៀបចំសារាចរអន្តរក្រសួងនេះ។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សារាចរអន្តរក្រសួង** ក្រោមពាក្យសារាចរអន្តរក្រសួង ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃសារាចរអន្តរក្រសួង។

ខ- ខ្លឹមសារនៃអត្ថបទ

ខ.១- សេចក្តីផ្តើម ត្រូវយោងទៅលិខិតបទដ្ឋានគតិយុត្តដែលត្រូវវិភាគនិងពន្យល់ដើម្បីបកស្រាយបញ្ជាក់ខ្លឹមសារឱ្យបានច្បាស់ឬត្រូវបង្ហាញអំពីបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្ត ដើម្បីឱ្យការអនុវត្តបន្តទទួលបានលទ្ធផលជាវិជ្ជមាន។

ខ.២- តួសេចក្តី ត្រូវចែងអំពីការកំណត់ខ្លឹមសារឬការបកស្រាយបញ្ហា ព្រមទាំងបណ្តាវិធានការដែលត្រូវសហការអនុវត្តឱ្យបានច្បាស់លាស់តាមផ្លូវច្បាប់។

ខ.៣- អវសានបទ ត្រូវចែងថា ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង...(ឬស្ថាប័ន...) និងក្រសួង...(ឬស្ថាប័ន...) (ឈ្មោះស្ថាប័នដែលចេញសារាចរអន្តរក្រសួងនេះ) ត្រូវសហការ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង(និង/ឬ ស្ថាប័ន)រៀងៗខ្លួនវិញ។

គ- រូបមន្តបញ្ចប់ នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃសារាចរអន្តរក្រសួង។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ស្របតាមទីតាំងនៅក្បាលលិខិត ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខានិងឈ្មោះរបស់ប្រធានស្ថាប័នឬប្រធានស្ថាប័នស្តីទីទាំងនោះ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះស្ថាប័ន អង្គភាពសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត មានជាអាទិ៍ ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គនាយកដ្ឋាន នាយកដ្ឋាន សាលារាជធានី ខេត្ត មន្ទីរជំនាញរាជធានី ខេត្ត រាជកិច្ច និងឯកសារកាលប្បវត្តិ។

សូមមើលគំរូទម្រង់នៃសារាចរអន្តរក្រសួង នៅទំព័រទី១២៤។

គំរូទម្រង់នៃសារាចរអន្តរក្រសួង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័នដើម)

**ក្រសួង** :... (ឈ្មោះក្រសួង ស្ថាប័នដើម) **ក្រសួង**... **ក្រសួង**...

**លេខ** :... (អក្សរកាត់របស់ក្រសួង ស្ថាប័នដើម)

**សារាចរអន្តរក្រសួង**
**ស្តីពី**

(ចំណងជើងជាអក្សរមូល)

(សេចក្តីផ្តើម)

..........................................................................................................................................។

(តួសេចក្តី)

(គោលបំណង)..........................................................................................................។

(ខ្លឹមសារណែនាំ)......................................................................................................។

(អវសានបទ)

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង...(ឬស្ថាប័ន...) និងក្រសួង...(ឬស្ថាប័ន...) (ឈ្មោះស្ថាប័នដែលចេញសារាចរអន្តរក្រសួងនេះ) ត្រូវសហការ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង (និង/ឬស្ថាប័ន) រៀងៗខ្លួនវិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...**(ឬប្រធានស្ថាប័ន)
(ហត្ថលេខានិងត្រា)
**(ឈ្មោះ)**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...**(ឬប្រធានស្ថាប័ន)
(ហត្ថលេខានិងត្រា)
**(ឈ្មោះ)**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...**(ឬប្រធានស្ថាប័ន)
(ហត្ថលេខានិងត្រា)
**(ឈ្មោះ)**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គនាយកដ្ឋាន
- នាយកដ្ឋាន
- សាលារាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**៤- ការបញ្ជូនសំណុំឯកសារទៅទីស្តីការគណៈរដ្ឋមន្ត្រី**

ក្រសួង ស្ថាប័នសាមី ត្រូវរៀបចំសេចក្តីព្រាងអត្ថបទដោយភ្ជាប់ជាមួយនូវកម្មវិធីនៃការកសាងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ហើយបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី(អគ្គលេខាធិការរាជរដ្ឋាភិបាល)។

**៤.១- សេចក្តីស្នើច្បាប់ដែលស្នើសុំឱ្យរាជរដ្ឋាភិបាលផ្តល់អនុសាសន៍**

សេចក្តីស្នើច្បាប់ដែលគណៈកម្មការរបស់ព្រឹទ្ធសភាឬរដ្ឋសភាស្នើឱ្យរាជរដ្ឋាភិបាលផ្តល់យោបល់ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មានភារកិច្ចធ្វើទំនាក់ទំនងយកសេចក្តីស្នើច្បាប់នោះពីស្ថាប័ននីតិប្បញ្ញត្តិមកជូនរាជរដ្ឋាភិបាលធ្វើការសិក្សានិងផ្តល់អនុសាសន៍ ដោយធ្វើទៅទីស្តីការគណៈរដ្ឋមន្ត្រីតាមរយៈលិខិតបញ្ជូនដែលចុះហត្ថលេខាដោយប្រធានស្ថាប័ន។ បន្ទាប់ពីបានទទួលលិខិតនោះ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវបញ្ជូនសេចក្តីស្នើច្បាប់ទៅឱ្យក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពិនិត្យនិងផ្តល់យោបល់។

ក្រសួង ស្ថាប័នជំនាញ ត្រូវចាត់ចែងពិនិត្យនិងពិភាក្សាក្នុងក្របខ័ណ្ឌសមត្ថកិច្ចនិងបច្ចេកទេសរបស់ខ្លួន រួចលើកយោបល់កែសម្រួលបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីវិញ ដោយភ្ជាប់ជាមួយនូវៈ

- លិខិតបញ្ជូនរបស់ក្រសួង ស្ថាប័នដែលចុះហត្ថលេខាដោយប្រធានស្ថាប័ន
- របាយការណ៍ពន្យល់បកស្រាយអំពីចំណុចដែលក្រសួង ស្ថាប័នជូនយោបល់កែសម្រួលតាមចំណុចមាត្រានីមួយៗ ដោយធ្វើជាតារាងប្រៀបធៀបរវាងបទប្បញ្ញត្តិដើមដែលចែងក្នុងសេចក្តីស្នើច្បាប់ និងបទប្បញ្ញត្តិដែលស្នើចែងថ្មី តាមទម្រង់ដូចបានកំណត់ក្នុងកថាខណ្ឌនៃចំណុច ៣.២.៣ ស្តីពីទម្រង់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់។

**៤.២- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ**

សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ត្រូវញែកនិងចែងជាលម្អិតឱ្យបានច្បាស់លាស់ តាមការកំណត់នៃច្បាប់ស្តីពីរបបគ្រប់គ្រងថវិកានិងប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា៣៩នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨។

**៤.៣- សេចក្តីព្រាងច្បាប់ដែលពាក់ព័ន្ធនឹងវិស័យតុលាការ**

អនុលោមតាមមាត្រា១០នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សេចក្តីស្នើច្បាប់ឬសេចក្តីព្រាងច្បាប់ដែលទាក់ទងនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃវិស័យតុលាការ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីផ្តល់យោបល់ជាចាំបាច់។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវផ្តល់យោបល់យ៉ាងយូរក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ឬសេចក្តីព្រាងច្បាប់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីប្រញាប់ រយៈពេលនេះអាចបន្ថយមកនៅត្រឹម១០ថ្ងៃ។

**៥- ការពិនិត្យសំណុំឯកសារនៅទីស្តីការគណៈរដ្ឋមន្ត្រី**

សំណុំឯកសារនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលការិយាល័យរបៀបនៃនាយកដ្ឋានរដ្ឋបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រីទទួលបាន ត្រូវបញ្ជូនទៅអគ្គលេខាធិការរាជរដ្ឋាភិបាល។

អគ្គលេខាធិការរាជរដ្ឋាភិបាលពិនិត្យសំណុំឯកសារនិងឆ្លើយតបពីការទទួលបានសំណុំឯកសារ។ ប្រសិនបើសំណុំឯកសារមិនទាន់ត្រឹមត្រូវនិង/ឬមានការខ្វះខាត អគ្គលេខាធិការរាជរដ្ឋាភិបាលត្រូវជម្រាបជូនក្រសួង ស្ថាប័នសាមីឱ្យបំពេញចំណុចទាំងនោះឡើងវិញ។ សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេង

ទៀតដែលអគ្គលេខាធិការរាជរដ្ឋាភិបាលបានយល់ព្រមទទួល ត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

**៥.១- ការពិនិត្យដោយអង្គប្រជុំជំនាញបច្ចេកទេស**

អង្គប្រជុំជំនាញបច្ចេកទេសដឹកនាំដោយតំណាងក្រុមប្រឹក្សាអ្នកច្បាប់និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាសហប្រធាន និងចូលរួមដោយតំណាងក្រសួង ស្ថាប័នសាមីនិងតំណាងផ្នែកជំនាញពាក់ព័ន្ធ ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់លើទិដ្ឋភាពគោលនយោបាយ ទិដ្ឋភាពច្បាប់ ទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងផ្តល់ទស្សនៈ ហេតុការណ៍ ព័ត៌មាន និងពិភាក្សាហេតុផលប៉ះពាល់ ព្រមទាំងពិនិត្យកែលម្អ ទម្រង់ ខ្លឹមសារ ពាក្យបច្ចេកទេស និងអក្ខរាវិរុទ្ធ។

សេចក្តីព្រាងអត្ថបទដែលបានឆ្លងអង្គប្រជុំជំនាញបច្ចេកទេសរួចហើយ អគ្គលេខាធិការរាជរដ្ឋាភិបាល ត្រូវរៀបចំដាក់ឆ្លងអង្គប្រជុំអន្តរក្រសួង។ ចំពោះសេចក្តីព្រាងអត្ថបទដែលអង្គប្រជុំជំនាញបច្ចេកទេសសម្រេចឱ្យកែសម្រួល ក្រសួង ស្ថាប័នសាមីត្រូវកែសម្រួលតាមស្មារតីអង្គប្រជុំ ដើម្បីដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេសសាឡើងវិញ។

**៥.២- ការពិនិត្យដោយអង្គប្រជុំអន្តរក្រសួង**

អង្គប្រជុំអន្តរក្រសួងដឹកនាំដោយអគ្គលេខាធិការឬអគ្គលេខាធិការរងទី១រាជរដ្ឋាភិបាលនិងរដ្ឋលេខាធិការជាសហប្រធាន និងចូលរួមដោយតំណាងក្រសួង ស្ថាប័ននិងតំណាងផ្នែកជំនាញពាក់ព័ន្ធ ដើម្បីពិភាក្សាសម្របសម្រួលមតិយោបល់លើចំណុចដែលពុំទាន់ឯកភាពគ្នា មានជាអាទិ៍ ករណីត្រួតភារកិច្ចឬករណីខ្វះចន្លោះភារកិច្ចក្នុងការទទួលខុសត្រូវតាមវិស័យនិងអន្តរវិស័យ ព្រមទាំងបំពេញបន្ថែមខ្លឹមសារធ្វើឱ្យសេចក្តីព្រាងអត្ថបទមានសង្គតិភាព និងលក្ខណៈពេញលេញ។ បន្ទាប់មកក្រសួងយុត្តិធម៌មានភារកិច្ចពិនិត្យបន្ថែមលើជំពូកនិងមាត្រាស្តីពីទោសប្បញ្ញត្តិជាមួយក្រសួង ស្ថាប័នសាមី រួចបញ្ជូនមកអគ្គលេខាធិការរាជរដ្ឋាភិបាល ដើម្បីដាក់ប្រជុំត្រួតពិនិត្យជាចុងក្រោយ។

**៥.៣- ការពិនិត្យដោយអង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ**

សេចក្តីព្រាងអត្ថបទដែលបានឆ្លងអង្គប្រជុំអន្តរក្រសួងរួចហើយ អគ្គលេខាធិការរាជរដ្ឋាភិបាលត្រូវរៀបចំដាក់ឆ្លងអង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

**៥.៤- ការពិនិត្យដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រីឬនាយករដ្ឋមន្ត្រីស្តីទី ដើម្បីពិភាក្សានិងសម្រេចរាល់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលស្នើឡើងដោយក្រសួង ស្ថាប័ន។

ក្រោយពីទទួលបានការឯកភាពពីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីហើយ ក្រសួង ស្ថាប័នសាមីត្រូវកែសម្រួលសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយយោងតាមសេចក្តីជូនដំណឹងនៃអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាងកែសម្រួលនេះ ត្រូវបញ្ជូនទៅអគ្គលេខាធិការរាជរដ្ឋាភិបាលដើម្បីចាត់ចែងបន្តតាមនីតិវិធីទៅតាមប្រភេទនៃសេចក្តីព្រាងនីមួយៗ។

**៥.៥- ការពិនិត្យនិងការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់**

បន្ទាប់ពីទទួលបានយោបល់ពីក្រសួង ស្ថាប័នជំនាញ អគ្គលេខាធិការរាជរដ្ឋាភិបាលត្រូវ៖

- ដាក់សេចក្តីស្នើច្បាប់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

- ដាក់ជូនប្រមុខរាជរដ្ឋាភិបាល៖
  - ឆ្លើយតបជាផ្លូវការដោយផ្តល់អនុសាសន៍ទៅរដ្ឋសភាឬព្រឹទ្ធសភា ប្រសិនបើមាន
  - សម្រេចលើការបញ្ជូនតំណាងទៅចូលរួមបំភ្លឺគណៈកម្មការរបស់រដ្ឋសភាឬព្រឹទ្ធសភាដែលរៀបចំសេចក្តីស្នើច្បាប់នោះ ឬបំភ្លឺអង្គសភាទាំងមូលជាមួយគណៈកម្មការរបស់រដ្ឋសភាឬព្រឹទ្ធសភា ក្នុងករណីចាំបាច់លើលក្ខណៈបច្ចេកទេស ប្រសិនបើមានការអញ្ជើញជាផ្លូវការរបស់រដ្ឋសភាឬព្រឹទ្ធសភា។

## ៦- ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងការចុះហត្ថលេខាអម

ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីផ្ញើជូនប្រធានរដ្ឋសភាឬថ្វាយព្រះមហាក្សត្រឬជូនប្រមុខរាជរដ្ឋាភិបាល ត្រូវអនុវត្តតាមបែបបទដោយឡែកតាមប្រភេទនីមួយៗ។

### ៦.១- សេចក្តីព្រាងច្បាប់

ក្រសួង ស្ថាប័នសាមីត្រូវផ្ញើទំនាក់ទំនងយកសូហ្វកូពីនៃសេចក្តីព្រាងច្បាប់ពីអគ្គលេខាធិការរាជរដ្ឋាភិបាល រួចសហការជាមួយអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីកែសម្រួលតាមស្មារតីនៃអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ បន្ទាប់មកអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ត្រូវរៀបចំលិខិតស្នើរបស់ប្រមុខរាជរដ្ឋាភិបាលផ្ញើទៅប្រធានរដ្ឋសភាសុំពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងច្បាប់និងសេចក្តីថ្លែងហេតុរបស់រាជរដ្ឋាភិបាល រួចចាត់បញ្ជូនទៅរដ្ឋសភា។ ដោយឡែកចំពោះសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ អគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវផ្ញើទៅអគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិនូវរបាយការណ៍ស្តីពីលទ្ធផលនៃការប្រជុំពិនិត្យរបស់គណៈរដ្ឋមន្ត្រី ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងច្បាប់ដែលបានផ្ញើជូនទៅរដ្ឋសភា១ច្បាប់ផងដែរ។

### ៦.២- ព្រះរាជក្រឹត្យ

#### ៦.២.១- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ

ក- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា"បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... (លេខ) ខែ... (អក្សរ) ឆ្នាំ... (លេខ) "។

នៅទំព័របញ្ចប់ត្រូវរៀបចំដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខាអមតែប៉ុណ្ណោះ ដោយដាក់ថា"បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា" រួចបញ្ជូនថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា ដោយមានភ្ជាប់ជាមួយនូវលិខិតស្នើនិងកំណត់មូលហេតុសង្ខេបឬលិខិតស្នើដែលចែងពីមូលហេតុសង្ខេប។

ខ- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា "បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា"។ ក្នុងករណីនេះ ត្រូវមានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីដោយដាក់ថា "បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា" និងមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដើម្បីគោរពជូននាយករដ្ឋមន្ត្រី ដោយដាក់ថា "គោរពជូនសម្តេចតេជោ

ជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី"។ នៅពីក្រោមឃ្លានេះ ត្រូវដាក់មុខតំណែងរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ហើយមានហត្ថលេខានិងឈ្មោះ ដោយគ្មានត្រានិងកាលបរិច្ឆេទទេ។

**៦.២.២- ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តតួត ដែលប្រមុខរាជរដ្ឋាភិបាលប្រើឆន្ទានុសិទ្ធិស្នើឡើង**

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា "បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា" តែគ្មានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីទេ។

**៦.២.៣- ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស ការលើកលែងទោស និងការតែងតាំងចៅក្រម**

ការរៀបចំត្រូវអនុវត្តតាមនីតិវិធី ដែលបានកំណត់ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**៦.២.៤- ព្រះរាជក្រឹត្យស្តីពីការផ្តល់គ្រឿងឥស្សរិយយស**

ការរៀបចំត្រូវអនុវត្តតាមសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០១ ស្តីពីការរៀបចំបែបបទស្នើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា។

**៦.៣- អនុក្រឹត្យ**

**៦.៣.១- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ**

ក- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ឬសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល

អនុក្រឹត្យដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា "បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី...(លេខ) ខែ...(អក្សរ) ឆ្នាំ...(លេខ)" ។ ក្នុងករណីសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល ត្រូវដាក់ថា "យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល" ។ អនុក្រឹត្យទាំងពីរបែបនេះ ត្រូវដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខា ដោយគ្មានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទេ។

ខ- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា "យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី) "។ ក្នុងករណីនេះ ត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីគោរពជូននាយករដ្ឋមន្ត្រី ដោយដាក់ថា "បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រីសូមហត្ថលេខា"។ នៅពីក្រោមឃ្លានេះ ត្រូវដាក់មុខតំណែងរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ហើយមានហត្ថលេខានិងឈ្មោះ ដោយគ្មានត្រានិងកាលបរិច្ឆេទទេ។

**៦.៣.២- អនុក្រឹត្យមានលក្ខណៈជាឯកត្តតួត**

ក្នុងករណីមានសំណើពីក្រសួង ស្ថាប័ន សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា "យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី) "។ ក្នុងករណីសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល ត្រូវដាក់ថា "យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល"។ អនុក្រឹត្យទាំងពីរបែបនេះ មានតែហត្ថលេខារបស់នាយករដ្ឋមន្ត្រីប៉ុណ្ណោះ។

## ៧- ការបញ្ជូនសំណុំឯកសារទៅរដ្ឋសភា

សេចក្តីព្រាងច្បាប់ បន្ទាប់ពីបានការយល់ព្រមពីគណៈរដ្ឋមន្ត្រីរួចហើយ អគ្គលេខាធិការដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រីច្បាប់ ត្រូវបញ្ជូនទៅរដ្ឋសភាដោយភ្ជាប់ជាមួយនូវឯកសារ ដូចតទៅ៖

- លិខិតស្នើរបស់ប្រមុខរាជរដ្ឋាភិបាល ជូនប្រធានរដ្ឋសភា
- សេចក្តីថ្លែងហេតុដែលបង្ហាញពីគោលដៅនិងអត្ថប្រយោជន៍នៃការរៀបចំសេចក្តីព្រាង
- សេចក្តីព្រាងអត្ថបទដែលបានកែសម្រួលតាមការសម្រេចរបស់អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

ដោយឡែក ចំពោះសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលដាក់ជូនរដ្ឋសភាអនុម័ត ត្រូវភ្ជាប់ជាមួយនឹងលិខិតស្នើរបស់ប្រមុខរាជរដ្ឋាភិបាលនូវឯកសារ ដូចមានចែងក្នុងមាត្រា៤៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។

## ៨- ការប្រគល់ភារកិច្ចឱ្យទៅការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភានិងព្រឹទ្ធសភា

ជាធម្មតា រាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យប្រធានស្ថាប័នសាមី ទៅការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភានិងព្រឹទ្ធសភា។ ក្នុងករណីដែលប្រធានស្ថាប័នជាប់បំពេញបេសកកម្មនៅក្រៅប្រទេស ប្រធានស្តីទីរបស់ស្ថាប័នត្រូវទៅការពារជំនួសតាមកាលកំណត់របស់រដ្ឋសភានិងព្រឹទ្ធសភា។

ប្រធានស្ថាប័នដែលជាប់បំពេញបេសកកម្មនៅក្នុងប្រទេស ហើយបានទទួលការអញ្ជើញពីរដ្ឋសភានិងព្រឹទ្ធសភាឱ្យទៅការពារសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ឈប់បេសកកម្មជាបន្ទាន់ ហើយត្រូវទៅការពារសេចក្តីព្រាងច្បាប់ តាមកាលកំណត់របស់រដ្ឋសភានិងព្រឹទ្ធសភា។ ក្នុងករណីមានធុរៈមិនអាចចូលរួមប្រជុំបាន ត្រូវចាត់តាំងអនុប្រធានស្ថាប័នឱ្យចូលរួមការពារសេចក្តីព្រាងច្បាប់នោះ។

## ៩- នីតិវិធីនិងវិធាននៃការសុំធ្វើវិសោធនកម្មច្បាប់និងសេចក្តីព្រាងច្បាប់

### ៩.១- ការធ្វើវិសោធនកម្មច្បាប់ជាធរមាន

ក្រសួង ស្ថាប័នសាមីអាចសុំធ្វើវិសោធនកម្មច្បាប់ជាធរមានបាន ប្រសិនបើពិនិត្យឃើញថាមានចំណុចដែលមិនអាចអនុវត្តបានក្នុងស្ថានភាពបច្ចុប្បន្នឬប៉ះពាល់ដល់ស្ថិរភាពសង្គម។ ចំពោះនីតិវិធីនៃការតាក់តែងសេចក្តីព្រាងនេះ ត្រូវដំណើរការរៀបចំដូចនីតិវិធីនៃការតាក់តែងសេចក្តីព្រាងច្បាប់ដែរ។

### ៩.២- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងរបៀបវារៈរបស់អង្គប្រជុំរដ្ឋសភា

ក្នុងពេលដែលរដ្ឋសភាកំពុងប្រជុំពិភាក្សា រាជរដ្ឋាភិបាលអាចផ្ញើលិខិតទៅរដ្ឋសភាដើម្បីសុំកែប្រែយ៉ាងជ្រាលជ្រៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ឬក៏អាចប្រគល់ភារកិច្ចឱ្យប្រធានស្ថាប័នសាមី ធ្វើទំនាក់ទំនងកែសម្រួលលើចំណុចដែលត្រូវកែប្រែ។ បទអន្តរាគមន៍នេះអាចធ្វើទៅបាន លុះណាតែមានការយល់ព្រមជាមុនពីគណៈរដ្ឋមន្ត្រីឬប្រមុខរាជរដ្ឋាភិបាល។

### ៩.៣- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងគណៈកម្មការនៃរដ្ឋសភា

ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលស្ថិតនៅក្នុងគណៈកម្មការនៃរដ្ឋសភា ប្រធានស្ថាប័នឬតំណាងអាចសម្របសម្រួលធ្វើការកែប្រែលើពាក្យពេចន៍ ល្បះ អក្ខរាវិរុទ្ធខ្លះៗបាន។ ចំពោះសំណើកែប្រែយ៉ាងជ្រាលជ្រៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់របស់ក្រសួង ស្ថាប័នសាមីឬរបស់គណៈកម្មការរដ្ឋសភា ត្រូវសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីឬពីប្រមុខរាជរដ្ឋាភិបាលឡើងវិញ។

## ១០- ការចូលជាធរមាននៃច្បាប់ក្រោយពីការអនុម័តនិងការយល់ព្រមរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងការចុះក្នុងរាជកិច្ច

ក្រោយពីទទួលបានអត្ថបទច្បាប់ដែលបានទទួលការអនុម័តពីរដ្ឋសភានិងទទួលការយល់ព្រមពីព្រឹទ្ធសភាហើយនោះ អគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវរៀបចំសេចក្តីព្រាងព្រះរាជក្រមជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា។

លិខិតដែលរាជរដ្ឋាភិបាលត្រូវថ្វាយព្រះមហាក្សត្រ មានៈ

- លិខិតរបស់ប្រមុខរាជរដ្ឋាភិបាលក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
- សេចក្តីព្រាងព្រះរាជក្រម ដែលមានហត្ថលេខាអមរបស់ប្រធានស្ថាប័នសាមីនិងរបស់នាយករដ្ឋមន្ត្រី និងច្បាប់ថ្វាយភ្ជាប់។

ច្បាប់ដែលព្រះមហាក្សត្រប្រកាសឱ្យប្រើតាមព្រះរាជក្រម ត្រូវចូលជាធរមានក្នុងរយៈពេល១០ថ្ងៃនៅភ្នំពេញ និង២០ថ្ងៃនៅទូទាំងប្រទេស បន្ទាប់ពីថ្ងៃដែលព្រះអង្គបានឡាយព្រះហស្តលេខា ប៉ុន្តែបើចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ។ បន្ទាប់មកអគ្គលេខាធិការរាជរដ្ឋាភិបាលត្រូវរៀបចំ និងចុះហត្ថលេខាលើសំណៅដែលមានតម្លៃជាការចែកផ្សាយនៃព្រះរាជក្រមដើម្បីចែកផ្សាយ។

ចំពោះច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវចុះផ្សាយក្នុងរាជកិច្ច ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី មានភារកិច្ចពិនិត្យរាល់អត្ថបទដែលត្រូវចុះផ្សាយក្នុងរាជកិច្ច ឱ្យស្របតាមច្បាប់ជាធរមានទាំងខ្លឹមសារទាំងទម្រង់។ បន្ទាប់ពីបានពិនិត្យត្រឹមត្រូវហើយ ក្រុមប្រឹក្សាអ្នកច្បាប់ត្រូវបញ្ជូនទៅអគ្គលេខាធិការរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេច ហើយចុះហត្ថលេខាយល់ព្រមឱ្យចុះផ្សាយក្នុងរាជកិច្ច។ អគ្គនាយកដ្ឋានរាជកិច្ចនិងសេវាកុំព្យូទ័រនៃទីស្តីការគណៈរដ្ឋមន្ត្រីមានភារកិច្ចទទួលចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់តាមតម្រូវការរបស់ក្រសួង ស្ថាប័នបញ្ជាទិញ។

ក្រសួង ស្ថាប័នសាមីអាចយកទៅធ្វើការបោះពុម្ពសម្រាប់ប្រើចំពោះច្បាប់ដែលបានចុះលេខលើសំណៅដែលមានតម្លៃជាការចែកផ្សាយ និងបានចុះក្នុងរាជកិច្ចរួចហើយ។ សៀវភៅដែលត្រូវបោះពុម្ព អាចដាក់បញ្ចូលនូវអត្ថបទបកប្រែជាភាសាបរទេស ដែលក្រុមប្រឹក្សាអ្នកច្បាប់បានទទួលស្គាល់ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៩៩ សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ០៦ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា

## សម្រេច

**ប្រការ១.**

លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១. អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ រូប | ប្រធាន |
| ២. អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ ០១ រូប | អនុប្រធាន |
| ៣. ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៤. អនុប្រធាននាយកដ្ឋានថវិកា ០១ រូប | សមាជិក |
| ៥. អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច ០១ រូប | សមាជិក |
| ៦. មន្ត្រី ០១ រូប | លេខា។ |

លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** អាចប្រើប្រាស់មន្ត្រីរបស់អគ្គលេខាធិការរងទទួលបន្ទុកជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ក្នុងករណីចាំបាច់។

**ប្រការ២.**

សមាជិករបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានលេខាធិការដ្ឋាន។

ក្នុងករណីអវត្តមាន ប្រធាន អាចផ្ទេរសិទ្ធិ ជូនអនុប្រធាន ឬសមាជិកណាម្នាក់ ដើម្បីកោះអញ្ជើញនិងដឹកនាំការប្រជុំរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.**។

**ប្រការ៣.**

លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.គ.** មានតួនាទីនិងភារកិច្ច ដូចតទៅ÷

១. ធ្វើជាសេនាធិការបច្ចេកទេសនិងរដ្ឋបាលជូនគណៈកម្មាធិការ **ប.ស.ប.គ.** និងសម្របសម្រួលការងារបច្ចេកទេសជាមួយ ក្រសួង ស្ថាប័ន ទាំងអស់ក្នុង **ប.ស.ប.គ.**

២. ធ្វើកំណត់ហេតុនិងរៀបចំរបាយការណ៍ប្រជុំរបស់គណៈកម្មាធិការ **ប.ស.ប.គ.**

៣. បំពេញតួនាទីជាអង្គភាពអនុវត្តនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុង **ប.ស.ប.គ.** តាមភារកិច្ចដូចខាងក្រោម÷

- គ្រប់គ្រងគណនីតម្កល់មូលនិធិប្រាក់បម្រុងសម្រាប់កិច្ចលទ្ធកម្ម ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងស្បៀងនិងគ្រាប់ពូជបម្រុងសម្រាប់ **ប.ស.ប.គ.**
- តាមដាន និងត្រួតពិនិត្យការប្រើប្រាស់មូលនិធិប្រាក់បម្រុង ក្នុងការទិញស្បៀងនិងគ្រាប់ពូជបម្រុងសម្រាប់ **ប.ស.ប.គ.**
- រៀបចំបម្រុងទុកថវិកាសម្រាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងពាណិជ្ជកម្មនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការថែរក្សាស្បៀងនិងគ្រាប់ពូជ ការផលិតគ្រាប់ពូជ ប្រតិបត្តិការសង្គ្រោះបន្ទាន់ និងប្រតិបត្តិការផ្សេងៗ ដែលទាក់ទងនឹង **ប.ស.ប.គ.**
- រៀបចំបូកសរុបថវិកាប្រចាំឆ្នាំរបស់ **ប.ស.ប.គ.** ដែលស្នើឡើងដោយក្រសួងពាណិជ្ជកម្ម សម្រាប់ស្បៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់គ្រាប់ពូជ ដើម្បីស្នើសុំការអនុម័ត ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- គ្រប់គ្រងថវិកាទាំងអស់របស់ **ប.ស.ប.គ.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាសនិងតាមការចាំបាច់ ជូននាយករដ្ឋមន្ត្រី និងជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ អំពីសភាពការណ៍ទូទៅរបស់ **ប.ស.ប.គ.**
- រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ **ប.ស.ប.គ.**

៣. បំពេញការងារផ្សេងទៀតតាមការចាំបាច់ ដែលប្រគល់ជូនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬប្រធានគណៈកម្មាធិការ **ប.ស.ប.គ.**។

**ប្រការ៤.**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធាននាយកដ្ឋាន និង ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ភ.** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- កាកបាទក្រហមកម្ពុជា
  “ដើម្បីជូនជ្រាប”
- ដូចប្រការ៤
  “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៩៩ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាសភាព
# លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ០៦ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- បានឃើញប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា

## សម្រេច

**ប្រការ១.**

ត្រូវបានតែងតាំងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **វង់ សណ្ដាប់** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោក **ខុង្ស ម៉ុនឥន្ទ្រាទុធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| ៣. | លោក **ហ៊ែល ចំរើន** ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៤. | លោក **មាស ចាន់ដេត** អនុប្រធាននាយកដ្ឋានថវិកា | សមាជិក |
| ៥. | លោក **អ៊ុន សុម៉េធ** អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| ៦. | លោក **លុន ម៉ារ៉ែត** ជំនួយការ ឯកឧត្តម **វង់ សណ្ដាប់** | លេខា។ |

**ប្រការ២.**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធាននាយកដ្ឋាន និង

ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.គ.** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- កាកបាទក្រហមកម្ពុជា

“ដើម្បីជូនជ្រាប”

- ដូចប្រការ២

“ដើម្បីអនុវត្ត”

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ